ឧបសម្ព័ន្ធ ក: សំណើសុំដាក់

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អវតក-អជសង/អជតក
ភាគីដាក់ឯកសារ៖ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម៖ អង់គ្លេស
កាលបរិច្ឆេទឯកសារ៖ [កាលបរិច្ឆេទ] ឆ្នាំ២០២០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ៖ **សាធារណៈ/Public**
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

[សំណើសុំដាក់]

**សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីស្ថានភាពនៃសំណុំរឿង ០០៤/០២ និងសិទ្ធិរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីនាំងនេះ**

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ហុង គឹមសួន
ឡោ ជុនធី
សំ សុគង់
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

នៅចំពោះមុខ៖

**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម C.N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

០០៤/២/០៧-០៩-២០០៩-អវតក-អជសង/អជតក

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា** **សហមេធាវីការពារក្តី អោ អាន**

ជា លាង មុំ លុជ្ស

Brenda HOLLIS Richard ROGERS

Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

Laure DESFORGES

Isabelle DURAND

គីម ម៉េងឃី

Lyma NGUYEN

ស៊ិន សុវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

# I. សេចក្តីផ្តើម

1. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវី") សូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ធ្វើការពិចារណាឱ្យបានពេញលេញលើការយល់ឃើញ និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខដែលកំពុងរង់ចាំសេចក្តីសម្រេច។ ជាពិសេស សហមេធាវីសន្និដ្ឋានថា យោងតាមក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក អ.ជ.ត.ក គួរសម្រេចថា អង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ដ) បានទទួលសំណុំរឿង ០០៤/២ ហើយរាល់វិធានរដ្ឋបាលឆ្លើយតបទៅនឹងសំណុំរឿងនេះ គួរអនុវត្តដើម្បីសម្រួលដល់ដំណើរការនីតិវិធី និងធានាឱ្យធ្វើការជំនុំជម្រះឆាប់រហ័ស។ សហមេធាវីក៏បានស្នើសុំឱ្យអង្គជំនុំជម្រះ ទទួលស្គាល់ការបំពានធ្ងន់ធ្ងរ និងការបន្តរំលោភសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤/២។

2. សេចក្តីសន្និដ្ឋានរបស់សហមេធាវីមានហេតុផលត្រឹមត្រូវដោយសំអាងលើទឡ្ហីករណ៍គួរឱ្យជឿជាក់បាន ដែលមាននៅក្នុងក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ តាមការពិត ការបកស្រាយសមហេតុផលនៃក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក តម្រូវឱ្យបញ្ជូនសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") នៅក្នុងរឿងក្តីនេះ។ អ.ជ.ស.ដ មានកំហុសអង្គច្បាប់ដោយបានសន្និដ្ឋានថា ខ្លួនមិនបានទទួលសំណុំរឿង ០០៤/២ នោះទេ។ តាមការពិនិត្យកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ក្នុងន័យត្រង់ ដោយបកស្រាយផ្អែកលើកម្មវត្ថុ និងគោលបំណងទៅតាមលក្ខខណ្ឌនៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ("អ.ញ.វ.ច.ស.ញ") បង្ហាញយ៉ាងច្បាស់ថា ការស៊ើបអង្កេត "ត្រូវបន្តទៅមុខ" លើកលែងតែសម្លេងភាគច្រើនលើសលប់សម្រេចយ៉ាងច្បាស់ផ្សេងពីនេះ។ ដូចគ្នានោះដែរ ច្បាប់កម្ពុជា រួមទាំងកាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ ដែលបញ្ចូលដោយផ្ទាល់នៅក្នុងច្បាប់នោះ បានណែនាំថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន ត្រូវបញ្ជូនទៅទៅជំនុំជម្រះនៅក្នុងកាលៈទេសៈទាំងនេះ។

3. ស្រដៀងគ្នានេះដែរ ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក កំណត់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ មានសិទ្ធិទទួលបានសវនាការ ទទួលបានសច្ចភាពផ្លូវច្បាប់ តម្លាភាព និងការផ្សព្វផ្សាយជាសាធារណៈនូវកិច្ចដំណើរការនីតិវិធីទាំងនេះ ដែលសិទ្ធិទាំងអស់នេះត្រូវបានរំលោភបំពានម្តងហើយម្តងទៀត ដោយសារសំណុំរឿង ០០៤/២ ស្ថិតក្នុងស្ថានភាពមួយពុំច្បាស់លាស់។ សហមេធាវីសូមស្នើសុំ អ.ជ.ត.ក ទទួលស្គាល់ និងសម្រេចថាមានការរំលោភបំពានសិទ្ធិទាំងនេះ ដោយចាត់វិធាន

ការធានាសេចក្ដីថ្លៃថ្នូរ និងសុខមាលភាពរបស់ជនរងគ្រោះ ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី នៃសំណុំរឿង ០០៤/២ ។

4. អនុលោមតាមសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ចុះ [បញ្ចូលកាលបរិច្ឆេទ] ២០២០ សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមគោរពដាក់ជូនការយល់ឃើញអំពីស្ថានភាពនៃកិច្ចដំណើរការ នីតិវិធីក្នុងសំណុំរឿង ០០៤/២ និងវិធានការចាំបាច់នានាដើម្បីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋ ប្បវេណី និងជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។ ដើម្បីមានភាពងាយស្រួល សហ មេធាវីសូមដាក់ពាក្យសេចក្ដីសន្និដ្ឋាននេះជាភាសាអង់គ្លេសជាមុនសិន ហើយសំណៅជាភាសាខ្មែរ នឹងដាក់ជូនតាមក្រោយភ្លាមៗបន្ទាប់ពីបានបកប្រែរួចរាល់[1]។

## II. ប្រវត្តិនីតិវិធី

5. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញដីកាដំណោះ ស្រាយដាច់ដោយឡែកពីគ្នាចំនួន ០២ ក្នុងសំណុំរឿង ០០៤/២[2]។ ស.ច.ស ជាតិ បានសម្រេចថា អោ អាន មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬ ជា អ្នកទទួលខុសត្រូវខ្ពស់បំផុត និងបានលើកលែងការចោទប្រកាន់ប្រឆាំង អោ អាន ("ដីកាលើកលែង ការចោទប្រកាន់")[3]។ ផ្ទុយមកវិញ ស.ច.ស អន្តរជាតិ បានសម្រេចថា អ.វ.ត.ក ពិតជាមានយុត្តា ធិការលើ អោ អាន ហើយបានចោទប្រកាន់គាត់លើបទចោទជាច្រើន ("ដីកាបញ្ជូនរឿងទៅជំនុំ ជម្រះ")[4]។ ស្របជាមួយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស.ច.ស. អន្តរជាតិ បានចេញសេចក្ដី សម្រេចលើភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី ដោយក្នុងនោះបានសម្រេចបដិសេធ

---

[1] សារអេឡិចត្រូនិកពីលោកវ័ន្ត បញ្ញាណ អ្នកបកប្រែ អង្គភាពបកប្រែភាសា កម្មវត្ថុ៖ រយៈពេលប៉ាន់ស្មានសម្រាប់ការបកប្រែ ភាសា ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២០ (ដោយប៉ាន់ស្មានថា ប្រសិនបើដាក់សារណាដើម្បីបកប្រែភាសា នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២០ វានឹងបញ្ចប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ ក្នុងអំឡុងម៉ោងធ្វើការ)។

[2] សំណុំរឿង០០៤/២/០៦-០៩-២០០៩-អវតក ("សំណុំរឿង០០៤/០២") ឯកសារ D360 ដីកាដំណោះស្រាយរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ សំណុំរឿង០០៤/០២ ឯកសារ D359 ដីកាដំណោះស្រាយរបស់សហ ចៅក្រមស៊ើបអង្កេតជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[3] សំណុំរឿង០០៤/០២ ឯកសារ D359 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[4] សំណុំរឿង០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសំណុំរឿង ០០៤/២[5]។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (បណ្តឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)[6]។

6. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានចេញ សេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្តីពិចារណា") ប៉ុន្តែ ពុំអាចរកសម្លេងភាគច្រើនលើសលប់ដើម្បីសម្រេចថា តើត្រូវតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់[7]។ អ.ប.ជ មិនទាន់បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយនោះទេ។

7. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានផ្ញើលិខិតមួយច្បាប់ជូន អ.ជ.ស.ដ ដោយបានស្នើសុំពន្យារពេលកាលបរិច្ឆេទដែលកំណត់ផុតរយៈពេល ១៥ថ្ងៃ ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងបានស្នើសុំឱ្យ អ.ជ.ស.ដ កោះប្រជុំរៀបចំការជំនុំជម្រះ[8]។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ អោ អាន បានផ្ញើលិខិតមួយច្បាប់ជូន អ.ជ.ស.ដ ដោយបានស្នើសុំ អ.ជ.ស.ដ បញ្ជាក់ថា ខ្លួនមិនបានទទួលសំណុំរឿង ០០៤/២ ឬ បើមិនដូច្នោះទេ អ.ជ.ស.ដ ផ្តល់ការណែនាំអំពីការដាក់អញ្ញត្រកម្ម[9]។ ទាំង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហមេធាវីនាំមុខតំណាង

[5] សំណុំរឿង០០៤/០២ ឯកសារ D362 ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[6] សំណុំរឿង០០៤/០២ ឯកសារ D362/5 បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

[7] សំណុំរឿង០០៤/០២ ឯកសារD359/24 & D360/33 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[8] សំណុំរឿង០០៤០២/ ឯកសារ E004/2/1.2.18 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបន្ថែមពេលវេលាដាក់បញ្ជីសាក្សី និងអ្នកជំនាញរបស់គាត់ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

[9] សំណុំរឿង០០៤០២/ ឯកសារ D359/27.1.1 សំណើសុំបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូង ពុំបានទទួលស្របច្បាប់នូវសំណុំរឿង០០៤/២ និងសុំពន្យារពេល និងគោលការណ៍ណែនាំសម្រាប់ដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

ដើមបណ្តឹងរដ្ឋប្បវេណី ពុំត្រូវបានចម្លងជូនលិខិតឆ្លើយឆ្លងណាមួយនោះឡើយ។ តាមអ្វីដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដឹង អ.ជ.ស.ជ មិនបានកោះប្រជុំរៀបចំការជំនុំជម្រះ ឬផ្តល់ការណែនាំអំពីការដាក់អញ្ញត្រកម្មនោះទេ។

8. កាលពីខែមករា និងកុម្ភៈ ឆ្នាំ២០២០ ស.ព.អ និងមេធាវីការពារក្តី អោ អាន បានដាក់ឯកសារជាទម្រង់ក្រដាស់យ៉ាងតិចចំនួន ០៥ ជូន អ.ជ.ស.ជ នៅក្នុងឯកសារថតចម្លងតាមរយៈផ្នែកគ្រប់គ្រងតុលាការ[10]។ ទោះបីជាឯកសារទាំងនេះទំនងជាបានចែកចាយជូន "មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤/២ ក៏ដោយ" ក៏ឯកសារទាំងនោះមិនត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធ Zylab ឬ ត្រូវបានជូនដំណឹងជាផ្លូវការតាមមធ្យោបាយណាមួយឡើយ[11] ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំបានទទួលច្បាប់ចម្លងនោះទេ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គ្រាន់តែបានដឹងអំពីការដាក់ឯកសារទាំងនោះតាមរយៈសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដែលត្រូវបាន ស.ព.អ និងមេធាវីការពារក្តី អោ អាន បញ្ជូន "ច្បាប់ចម្លង" ក្រៅផ្លូវការ[12]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំមានមធ្យោបាយបញ្ជាក់ថាគ្មានឯកសារផ្សេងទៀតត្រូវបានធ្វើឡើងដោយភាគីក្នុងសំណុំរឿង ០០៤/២ នោះទេ។

---

[10] សំណុំរឿង០០៤០២/ ឯកសារ **E004/2/1.2.20** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសំណើរបស់អោ អាន ទាក់ទងនឹងការទទួលយកសំណុំរឿង០០៤/២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។ សំណុំរឿង០០៤០២/ ឯកសារ **E004/2/1.2.21** បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ សំណុំរឿង០០៤០២/ ឯកសារ **E004/2/1.2.22** សេចក្តីសង្ខេបលើអញ្ញត្រកម្មរបស់អោ អាន តាមវិធាន៨៩ (១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។ សំណុំរឿង០០៤០២/ ឯកសារ **E004/2/1.2.23** ការដាក់ឈ្មោះបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់អោ អាន អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធ ១ សម្ងាត់ និងចម្លើយតបរបស់អោ អាន ចំពោះការដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។ សំណុំរឿង០០៤០២/ ឯកសារ **E004/2/1.2.24** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការដើម្បីទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់អោ អាន និងសំណុំរឿង០០៤/០២ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។

[11] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ថា ការដាក់ឯកសារជាក្រដាសដោយផ្ទាល់ គឺអាចអនុញ្ញាតទៅបាន។ *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី៨) មាត្រា២.១, ២.៥ ឆ្នាំ២០០៧។

[12] សារអេឡិចត្រូនិករបស់លោកស្រី Megan HIRST សហមេធាវីនាំមុខអន្តរជាតិ កម្មវត្ថុ៖ សារអេឡិចត្រូនិករបស់ អ.វ.ត.ក និងសំណុំរឿង០០៤/២ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០ (រៀបរាប់អំពីឯកសារសំណុំរឿង០០៤/២ ដែលបានចម្លងផ្ញើជូនសហមេធាវីនាំមុខ)។ សារអេឡិចត្រូនិករបស់លោកស្រី Megan HIRST សហមេធាវីនាំមុខអន្តរជាតិ កម្មវត្ថុ៖ ឯកសារថតចម្លងសំណើ

9. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ង បានផ្ញើអ៊ីមែលទៅចៅក្រម អ.ប.ជ ការិយាល័យរដ្ឋបាល អោ អាន និងសហព្រះរាជអាជ្ញា ទោះបីពួកគេដឹងអំពីសេចក្តីពិចារណាក៏ដោយ ដោយជូនដំណឹងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿងពាក់ព័ន្ធ មិនត្រូវបានផ្ទេរតាមនីតិវិធីរដ្ឋបាល ទៅ អ.ជ.ស.ង នោះឡើយ ដូច្នេះ ខ្លួនមិនអាចបំពេញកិច្ចលើសំណុំរឿងនេះទេ[13]។ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ង បានផ្ញើអ៊ីមែលជូនសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី អោ អាន ដោយបញ្ជាក់ជាថ្មីថា "អង្គជំនុំជម្រះសាលាដំបូងនៅតែមិនទាន់ត្រូវបានអង្គបុរេជំនុំជម្រះ ជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណានៅឡើយ។ សំណុំរឿងក្តីក៏ពុំមិនត្រូវបានប្តឹងមកនៅឡើយ។ វាអាស្រ័យលើអង្គបុរេជំនុំជម្រះជាអ្នកផ្តួចផ្តើមកិច្ចទាំងពីរនេះ"[14]។ ជាថ្មីម្តងទៀត ទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានចម្លងជូនលិខិតឆ្លើយឆ្លងទាំងនេះទេ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនមានមធ្យោបាយបញ្ជាក់ថាតើពួកគេត្រូវបានគេលុបចេញពីបញ្ជីអ្នកទទួលលិខិតឆ្លើយឆ្លងក្នុងសំណុំរឿង ០០៤/២ បញ្ជូនមកពីក្រឡាបញ្ជី អ.ជ.ស.ង ឬ មន្ត្រី អ.វ.ត.ក ដទៃទៀត មែនឬមិនមែន។

10. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ង បានផ្ញើអ៊ីមែលជូនចៅក្រម អ.ប.ជ ការិយាល័យរដ្ឋបាល អោ អាន សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយបានជម្រាបភាគីអំពីអ៊ីមែលរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២១ ខែមករា និងថ្ងៃទី១០ ខែកុម្ភៈ ដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួល ហើយបានកត់សម្គាល់ថា " បញ្ហាសំខាន់ ដែលត្រូវបានលើកឡើង កំពុងត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិប្តឹងនៅចំពោះមុខ

---

របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងចាត់វិធានការ ដើម្បីទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង០០៤/២ (អោ អាន) ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ (ឯកសារចម្លងនៃសារណានេះ មិនមានភ្ជាប់ជាមួយសារអេឡិចត្រូនិកឡើង ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនមានសិទ្ធិចូលពិនិត្យមើលឯកសារនេះពីព្រះរាជអាជ្ញាទេ))។

[13] សំណុំរឿង០០៤/០២ ឯកសារ D359/27.1.2 សារអេឡិចត្រូនិកពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ព័ត៌មាន, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២០។

[14] សំណុំរឿង០០៤/០២ ឯកសារ D359/27.1.3 សារអេឡិចត្រូនិកពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០២០, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ (ការគូសបញ្ជាក់ក្នុងច្បាប់ដើម)។

អង្គបុរេជំនុំជម្រះ”[15]។ អ៊ីមែលនោះក៏បានយោងផងដែរលើលិខិតឆ្លើយឆ្លងរបស់ ស.ព.អ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួល[16]។

11. ដើម្បីឆ្លើយតបទៅនឹងការប៉ុនប៉ងរបស់ ស.ព.អ ក្នុងការដាក់ឯកសារបន្ថែមទៀតកាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ អង្គជំនុំជម្រះសាលាដំបូងបានផ្ញើសាជាថ្មីម្តងទៀតជូនដល់ភាគីនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ ភាគច្រើន ប៉ុន្តែមិនទាំងអស់នោះទេ ត្រូវបានចម្លងជូនលិខិតឆ្លើយឆ្លងនេះ។

12. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានចេញអនុស្សរណៈអន្តរការិយាល័យតាមរយៈអ៊ីម៉ែលស្តីពី “ការផ្ទេរសំណុំរឿង ០០៤/២” និងភ្ជាប់ជាមួយនូវឯកសារ ដែលមានតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ប៉ុណ្ណោះត្រូវបានចម្លងជូន[17]។ ឯកសារភ្ជាប់បានរៀបរាប់លម្អិតអំពីជំហានជាច្រើន ដែលបានធ្វើឡើង ហើយជាញឹកញាប់មានលិខិតឆ្លើយឆ្លងផ្ទុយគ្នា ដែលធ្វើឡើងដោយចៅក្រម និងក្រឡាបញ្ជី អ.ប.ជ ទាក់ទងនឹងការផ្ទេរសំណុំរឿង ០០៤/២ ទៅ អ.ជ.ស.ង[18]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានចម្លងជូនលិខិតឆ្លើយឆ្លងទាំងនេះ ហើយនៅតែមិនដឹងអំពីការវិវឌ្ឍភាគច្រើនរហូតដល់ពេលចេញអនុស្សរណៈចុះថ្ងៃទី១២ ខែមីនា។

13. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ តាមឆន្ទានុសិទ្ធិបុគ្គល បានចេញអនុស្សរណៈអន្តរការិយាល័យតាមរយៈអ៊ីមែលស្តីពី “ការបញ្ជាក់ឡើងវិញអំពីសេចក្តីសម្រេចលើសំណុំរឿង ០០៤/២”[19]។ អនុស្សរណៈចុះថ្ងៃទី១៦ ខែមីនា បានបញ្ជាក់ថា មិន

---

[15] សារអេឡិចត្រូនិកពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ពាក់ព័ន្ធនឹងការទំនាក់ទំនងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០។

[16] *ដូចជើងទំព័រខាងលើ*។

[17] សំណុំរឿង០០៤/០២ ឯកសារ **D359/31.1.2** អនុស្សរណៈអន្តរការិយាល័យ ចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ, កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/០២ កថាខណ្ឌ ៥-២០ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

[18] *សូមមើល* ឯកសារភ្ជាប់១-៨ ទៅនឹងសំណុំរឿង០០៤/០២ ឯកសារ **D359/31.1.2** អនុស្សរណៈអន្តរការិយាល័យ ចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/០២, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០។

[19] សំណុំរឿង០០៤/០២ ឯកសារ **D359/31.1.1** អនុស្សរណៈអន្តរការិយាល័យ ចេញដោយចៅក្រមប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការបញ្ជាក់ឡើងវិញលើសេចក្តីសម្រេចក្នុងសំណុំរឿង០០៤/២ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

ចាំបាច់មានសកម្មភាពរដ្ឋបាលបន្ថែមទៀត ដែលត្រូវបានធ្វើឡើងដោយ អ.ប.ជ នោះឡើយ។ មានតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចតែប៉ុណ្ណោះ ដែលត្រូវបានចម្លងជូនលិខិតឆ្លើយឆ្លងនេះ។

14. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ មេធាវីចំនួន ៨រូប តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ បានដាក់សំណើសុំទៅ អ.ប.ជ ដោយបានរៀបរាប់លម្អិតអំពីការរំលោភបំពានធ្ងន់ធ្ងរ និងម្តងហើយម្តងទៀត និងការមិនគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះតម្លាភាព ភាពច្បាស់លាស់ផ្នែកច្បាប់ ការចូលរួម និងការប្រព្រឹត្តដោយយុត្តិធម៌ និងមានគុណភាពនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤/២[20]។ មកដល់ពេលនេះ អ.ប.ជ ពុំទាន់បានសម្រេចលើសំណើសុំនេះនៅឡើយទេ។

15. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ដ បានផ្ញើសេចក្តីថ្លែងការណ៍ជូនភាគីនានា (“សេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា”) តាមរយៈអ៊ីមែល ហើយបន្ទាប់មកបានផ្សព្វផ្សាយសេចក្តីថ្លែងការណ៍នោះនៅលើគេហទំព័ររបស់ អ.វ.ត.ក[21]។ សេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា បានជូនដំណឹងដល់ភាគីថា ចៅក្រមជាតិនៃ អ.ជ.ស.ដ ជឿជាក់ថា “នឹងមិនមានការជំនុំជម្រះក្តីលើ អោ អាន នៅពេលនេះ ឬ នៅពេលអនាគតនោះ”ឡើយ។

16. នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ជាបន្ទាន់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង[22]។

17. នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ (ប៉ុន្តែ បោះត្រាដោយមន្ត្រីគ្រប់គ្រងសំណុំរឿងនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០) ក្រុមមេធាវីការពារក្តី អោ អាន បានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ជាបន្ទាន់

[20] សំណុំរឿង០០៤/០២ ឯកសារ **D359/33** សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/០២ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។

[21] សេចក្តីថ្លែងការណ៍ របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក /ស្តីពីសំណុំរឿង ០០៤ .ក.ត.វ.២ ពាក់ព័ន្ធនឹង អោ អាន

https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao។

[22] សំណុំរឿង០០៤/០២ ឯកសារ **E004/2/1** បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០។

របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង[23]។

18. នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់ អោ អាន[24]។

19. នៅថ្ងៃ [កាលបរិច្ឆេទ] ឆ្នាំ២០២០ ដោយសារខ្វះភាពច្បាស់លាស់ទាក់ទងនឹងការតំណាងស្របច្បាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.ជ.ត.ក មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សំណើសុំ អ.ជ.ត.ក ចាត់វិធានការសមហេតុផលទាំងអស់ ដើម្បីទទួលស្គាល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ និងទទួលស្គាល់ ផ្ដល់ការអនុញ្ញាតឱ្យចូលមើលសំណុំរឿង និងដាក់ការយល់ឃើញរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីស្ថានភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ឬផ្ដល់សិទ្ធិនៅចំពោះមុខ អ.ជ.ត.ក ជូនទៅសហមេធាវី និងអនុញ្ញាតឱ្យពួកគេដាក់សារណាបន្ទាន់ដូចគ្នា។

20. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនស្ដីពី [កាលបរិច្ឆេទកាល] ឆ្នាំ២០២០ អ.ជ.ត.ក បានយល់ព្រមផ្ដល់សិទ្ធិដល់សហមេធាវី ដាក់សេចក្ដីសន្និដ្ឋានរបស់ពួកគេ ដោយរៀបរាប់លំអិតអំពីការយល់ឃើញរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីស្ថានភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២។

## III. សារណា

### ក. អ.ជ.ស.ជ បានទទួលសំណុំរឿង ០០៤/២ ហើយសំណុំរឿងនេះគួរបន្តនីតិវិធីជំនុំជម្រះភ្លាមៗ

#### ១. អ.ជ.ស.ជ មានកំហុសអង្គច្បាប់ដោយសារខកខានមិនបានទទួលស្គាល់ថា ខ្លួនបានទទួលសំណុំរឿង ០០៤/២ អនុលោមតាមក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក

[23] សំណុំរឿង០០៤/០២ ឯកសារ E004/2/1/1 ចម្លើយតបបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០។

[24] សំណុំរឿង០០៤/០២ ឯកសារ E004/2/1/1/1 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អោ អាន ទាក់ទងនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់គាត់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង០០៤២ របស់អង្គជំនុំជម្រះសាលា/ដំបូង ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០។

*ក. កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ចាំបាច់ត្រូវបកស្រាយ អនុលោមទៅតាមគោលការណ៍នៃការបកស្រាយសន្ធិសញ្ញា តាមច្បាប់អន្តរជាតិ ដូចដែលបានកំណត់ក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា*

21. បើតាមគោលការណ៍ការបកស្រាយសន្ធិសញ្ញា ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ដែលអនុវត្តជាទូទៅសម្រាប់គ្រប់សន្ធិសញ្ញាទាំងអស់ និងមានបញ្ចូលជាក់លាក់ នៅក្នុងមាត្រា ២(២) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក សន្ធិសញ្ញាចាំបាច់ត្រូវបកស្រាយ ដោយផ្អែកលើអត្ថន័យសាមញ្ញ ដែលធ្វើឡើងតាមបរិបទនៃគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញានោះ[25]។ មាត្រា ៣១(១) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា តម្រូវថា សន្ធិសញ្ញាត្រូវបកស្រាយ "ក្នុងសុឆន្ទៈ ស្របទៅតាមអត្ថន័យទូទៅនៃពាក្យពេចន៍ នៅក្នុងបរិបទ និងផ្អែកទៅលើគោលដៅ និងគោលបំណងរបស់វា"[26]។ មធ្យោបាយបកស្រាយបន្ថែមទៀត មានចែងនៅក្នុងមាត្រា ៣២ ដូចជា ការងារត្រៀមរៀបចំសន្ធិសញ្ញា និងបរិបទនៃសន្ធិសញ្ញានោះ អាចយោងបានដើម្បីគាំទ្រដល់អត្ថន័យរបស់ពាក្យពេចន៍ ក្នុងករណីដែលការបកស្រាយ តាមមាត្រា ៣១ បណ្តាលឲ្យមានលទ្ធផល "មិនច្បាស់លាស់ ឬស្រពិចស្រពិល" ឬលទ្ធផលដែល "ឆ្គងខ្លាំង ឬមិនសមហេតុផល"[27]។ លើសពីនេះទៀត ការអនុវត្តរបស់រដ្ឋ រួមទាំង កិច្ចព្រមព្រៀងនាពេលបន្ទាប់មករវាងភាគីនានា ឬការអនុវត្តសន្ធិសញ្ញានាពេលបន្ទាប់មក គឺជាមធ្យោបាយដ៏ត្រឹមត្រូវក្នុងការបកស្រាយសន្ធិសញ្ញា និងក្នុងករណីដែលមាន អាចជាកត្តាសម្រេចកំណត់[28]។

i. អត្ថន័យសាមញ្ញនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បង្ហាញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន គួរត្រូវបន្តទៅដំណាក់កាលជំនុំជម្រះ

22. កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានប្រមើលមើលថា ការខ្វែងយោបល់គ្នាអាចកើតមានឡើងរវាងសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងចៅក្រមអង្គបុរេជំនុំជម្រះ នៅដំណាក់កាលនានាក្នុងដំណើរការនៃសំណុំរឿង។ សម្រាប់ករណីនីមួយៗ អត្ថបទនៃកិច្ចព្រមព្រៀងស្តីពីការ

---

[25] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា មាត្រា ៣១ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ 1155 U.N.T.S. 331។

[26] ដូចជើងទំព័រខាងលើ មាត្រា ៣១(១)។

[27] ដូចជើងទំព័រខាងលើ មាត្រា ៣២។

[28] ដូចជើងទំព័រខាងលើ មាត្រា ៣១(៣)(ក), ៣១(៣)(ខ)។

បង្កើត អ.វ.ត.ក បានកំណត់ពីនីតិវិធី ដែលកំណត់ឱ្យបន្តកិច្ចស៊ើបសួរ ឬការជំនុំជម្រះ នៅពេលមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់។

23. មាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានចែងលម្អិតអំពីវិធាននីតិវិធីដែលគ្រប់គ្រងទៅលើការខ្វែងយោបល់គ្នានៅក្នុងអង្គបុរេជំនុំជម្រះ។ បើតាមពាក្យពេចន៍សាមញ្ញនៃមាត្រា ៧ "ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសម្លេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ [...] ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់ នឹង**__ត្រូវបន្តដំណើរការទៅមុខទៀត__**" (ដោយគូសបញ្ជាក់បន្ថែម)។ លើកលែងតែមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ប្រានចោលដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អត្ថន័យសាមញ្ញនៃមាត្រា ៧ តម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន ត្រូវបន្តដល់ដំណាក់កាលបន្ទាប់ នៃកិច្ចដំណើរការនីតិវិធី គឺការជំនុំជម្រះ។

24. បទប្បញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានឆ្លុះបញ្ចាំងប្រហែលគ្នាអំពីគោលការណ៍ដែលថា ការស៊ើបអង្កេត ឬការជំនុំជម្រះ ត្រូវបន្ត បើគ្មានសម្លេងភាគច្រើនលើសលប់សម្រេចផ្ទុយពីនេះ។ ជាឧទាហរណ៍ មាត្រា ៥(៤) ចែងថា ប្រសិនបើ "ចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំ ... ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧"។ ពាក្យពេចន៍ដូចគ្នានេះត្រូវបានប្រើប្រាស់នៅក្នុងមាត្រា ៦(៤) ដើម្បីកំណត់ពីដំណើរការដោះស្រាយទំនាស់ ក្នុងករណីដែលមានការខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា។

25. ដូចគ្នានេះដែរ អត្ថបទច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលជាផ្នែករួមគ្នានៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានស្នើឱ្យមានការបន្តកិច្ចស៊ើបសួរ ឬការជំនុំជម្រះ លើកលែងតែសេចក្តីសម្រេចដោយមតិភាគច្រើនលើសលប់សម្រេចផ្សេងពីនេះ។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបញ្ជាក់ថា ដំណោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត តម្រូវឱ្យមាន "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ" ដែល "តម្រូវឱ្យមានសម្លេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច" ហើយ "ប្រសិនបើពុំមានមតិភាគច្រើន ដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"។ បើតាមមាត្រា ២០ ថ្មី ដំណោះស្រាយការខ្វែងយោបល់គ្នារវាង

សហព្រះរាជអាជ្ញា តម្រូវប្រហែលគ្នាឲ្យមាន សម្លេងភាគច្រើនលើសលប់ ពីចៅក្រមបួនរូបនៅអង្គបុរេជំនុំជម្រះ ហើយប្រសិនបើមិនមានទេ "ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត"។

26. ក្នុងករណីនេះ ដោយគោរពទៅតាមនីតិវិធីដែលបានរៀបរាប់លម្អិតនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចោទប្រកាន់ថា អោ អាន ស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក[29]។ សហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចស៊ើបសួរ ដោយផ្អែកលើមូលដ្ឋាននៃដីកាសន្និដ្ឋាននេះ ដែលនាំទៅដល់ការចេញសេចក្តីសម្រេចខុសពីគ្នា ដែលថាតើ អោ អាន ត្រូវស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ។ ពាក្យពេចន៍ធម្មតានៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលលើកឡើងម្តងទៀតនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងច្បាស់ថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់បញ្ជូន អោ អាន ទៅជំនុំជម្រះ គួរត្រូវបន្តដល់អង្គជំនុំជម្រះសាលាដំបូង ប្រសិនបើមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះ សម្រេចផ្ទុយពីនេះ។ លទ្ធផលផ្សេងពីនេះគឺផ្ទុយទៅនឹងពាក្យពេចន៍សាមញ្ញនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលកម្ពុជា និងអង្គការសហប្រជាជាតិ បានឯកភាពជាផ្លូវការ។

[29] សំណុំរឿង ០០៤/២០-១១-២០០៨-អវតក ("សំណុំរឿង ០០៤") ឯកសារ **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩។ សំណុំរឿង ០០៤/២ ឯកសារ **D27** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១។ សំណុំរឿង ០០៤/២, ឯកសារ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មតំបន់១ និងការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោម ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១។ សំណុំរឿង ០០៤/២ ឯកសារ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ខែមេសា ឆ្នាំ២០១៤។ សំណុំរឿង ០០៤/២ ឯកសារ **D254/1** ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តអង្គតាមាក់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥។ សំណុំរឿង ០០៤/២ ឯកសារ **D272/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥។

ii. ការមិនបន្តទៅដំណាក់កាលជំនុំជម្រះ នឹងនាំទៅដល់លទ្ធផលដែលមិនសមទំនងធ្វើឱ្យមោឃភាពដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អៅ អាន ដែលផ្ទុយពីគោលដៅ និងគោលបំណង របស់កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក

27. អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា តម្រូវថា អត្ថបទនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ត្រូវបកស្រាយផ្អែកតាម "គោលដៅ និងគោលបំណង"[30] ដែលគាំទ្រថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អៅ អាន ត្រូវបន្តទៅជំនុំជម្រះ ប្រសិនបើមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ សម្រេចផ្សេងពីនេះ។

28. ជាដំបូង កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក កំណត់យ៉ាងច្បាស់ថា គោលដៅ និងគោលបំណងជាចម្បងរបស់ អ.វ.ត.ក គឺដើម្បីនាំយកជនសង្ស័យមកជំនុំជម្រះ។ មាត្រា ១ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានកំណត់ថា "គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម" ដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[31]។ មាត្រា ១១ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលហាមឃាត់រាជរដ្ឋាភិបាលកម្ពុជា មិនឱ្យស្នើសុំ "ការលើកលែងទោស ឬអនុគ្រោះទោសដល់ជនទាំងឡាយណា ដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ" បានគាំទ្របន្ថែមទៀតដល់សារសំខាន់ដែលអ្នកតាក់តែងសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានផ្តល់ដល់ការជំនុំជម្រះប្រកបដោយប្រសិទ្ធភាព[32]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបញ្ជាក់ប្រហែលគ្នាថា គោលដៅ និង

---

[30] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ដូចជើងទំព័រ ២៥ ខាងលើ មាត្រា ៣១-៣២។

[31] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា១ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ [ដែលចាប់ពីពេលនោះទៅហៅថា កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក]។

[32] សូមមើល ដូចជើងទំព័រខាងលើ មាត្រា១១។ សូមមើលផងដែរ ដូចជើងទំព័រខាងលើ បុព្វកថា ("**ដោយហេតុថា** អាជ្ញាធរកម្ពុជា បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិ **ដើម្បីកាត់សេចក្តី**មេដឹកនាំជាន់ខ្ពស់ កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦ មករា ១៩៧៩។ **ដោយហេតុថា** នៅមុនពេលចរចាលើកិច្ចព្រមព្រៀងនេះ មានឧបសម្ព័ន្ធ ក-ការបញ្ជាក់បំភ្លឺរបស់មេធាវីតំណាងរដ្ឋប្បវេណីៈ ពាក់ព័ន្ធនឹងតំណាងតាមផ្លូវច្បាប់

គោលបំណងជាចម្បងនៃការងាររបស់ អ.វ.ត.ក គឺនាំយកជនសង្ស័យមកជំនុំជម្រះ[33]។ ការបញ្ឈប់ផ្នែកនីតិវិធីទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន នៅដំណាក់កាលបុរេជំនុំជម្រះ ដោយមិនមានសេចក្តីសម្រេចជាក់លាក់ច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺផ្ទុយទាំងស្រុងជាមួយនឹងគោលដៅ និងគោលបំណងនេះ។

29. ទីពីរ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានកំណត់ពីការផ្តល់យុត្តិធម៌សម្រាប់ជនរងគ្រោះថាជាគោលដៅ និងគោលបំណងសំខាន់មួយទៀតរបស់ អ.វ.ត.ក។ បុព្វកថារបស់កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានគាំទ្រដល់ការប្តេជ្ញាចិត្តរបស់ អ.វ.ត.ក ក្នុងការផ្តល់សំណងដល់ជនរងគ្រោះ និងដល់សហគមន៍ជារួម ដោយសង្កត់ធ្ងន់ទៅលើគោលបំណងរបស់ អ.វ.ត.ក ដែលត្រូវធ្វើឱ្យមានគណនេយ្យភាពសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ហើយតុលាការគួរអនុវត្តតាម "ការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"[34]។ ជាពិសេស បុព្វកថាបានដកស្រង់សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលបានលើកឡើងថា "ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជា និងច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ... នៅតែជាបញ្ហាដែលបង្កឱ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល" និងទទួលស្គាល់ "ការព្រួយបារម្ភពេញច្បាប់ រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"[35]។

30. ក្នុងករណីមិនមានសម្លេងភាគច្រើនលើសលប់ សម្រេចផ្ទុយពីនេះ ការបន្តជំរុញដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់ អោ អាន ស្របទៅតាមអត្ថបទនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ហើយ

---

ការរីកចម្រើនជាច្រើនធ្វើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (បន្ទាប់ពីនេះហៅថា លោកអគ្គលេខាធិការ) និងរាជរដ្ឋាភិបាលកម្ពុជា ឈានទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ **ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម**ដែលបានប្រព្រឹត្តក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ") (ដោយគូសបញ្ជាក់បន្ថែម)។

[33] សូមមើល *ជាឧទាហរណ៍* ច្បាប់ស្តីពីការបង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ មាត្រា ១ និង ៤០ ថ្មី ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០១ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១៩៩៤/០០៦) [ដែលចាប់ពីពេលនោះទៅហៅថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក]។

[34] សូមមើល កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, បុព្វកថា។

[35] ដូចជើងទំព័រខាងលើ។

ស្របជាមួយគោលដៅរួមគ្នាពីរ គឺការនាំយកជនសង្ស័យមកជំនុំជម្រះ និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ។ ការអនុវត្តបែបនេះក៏មិនបានរំលោភបំពានទៅលើសិទ្ធិរបស់ជនត្រូវចោទ ដូចមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ សច្ចធារណ៍នៃនិរទោស សិទ្ធិទទួលបានការជំនុំជម្រះដែលយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការដែលមិនលម្អៀង និងការរួចផុតពីការអនុវត្តបែបប្រតិសកម្មទៅលើច្បាប់[36]។ ការអនុញ្ញាតឱ្យសំណុំរឿងបន្តទៅមុខ ក្នុងករណីមិនមានសម្លេងភាគច្រើនលើសលប់ នឹងមិនបង្កផលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ណាមួយខាងលើឡើយ។ សេចក្តីសម្រេចបែបនេះនឹងសំដៅតែទៅលើយុត្តាធិការរបស់តុលាការ ហើយមិនប៉ះពាល់ដល់ពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនសង្ស័យទេ ហើយក៏មិនពាក់ព័ន្ធជាមួយអង្គសេចក្តីនៃសំណុំរឿង ទោះជាតាមមធ្យោបាយណាក្តី។ ចំណុចគួរឱ្យកត់សម្គាល់ គឺ បើតាមក្របខណ្ឌ អ.វ.ត.ក អោ អាន អាចត្រូវបានផ្តន្ទាទោសតែចំពោះឧក្រិដ្ឋកម្មដែលមាននៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់របស់អង្គជំនុំជម្រះសាលាដំបូង (ឬជាចុងក្រោយដោយអង្គជំនុំជម្រះតុលាការកំពូល)។ ផ្ទុយទៅវិញ ការមិនជំរុញដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពទៅអង្គជំនុំជម្រះសាលាដំបូង គឺជាការលុបបំបាត់សិទ្ធិរបស់ជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌។

*ខ. មធ្យោបាយបន្ថែមក្នុងការបកស្រាយតាមមាត្រា ៣២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា គាំទ្របន្ថែមទៀតសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន ដែលត្រូវដំណើរការទៅដំណាក់កាលជំនុំជម្រះ*

i. ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក

---

[36] សូមមើល ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី (តម្រូវឱ្យអង្គជំនុំជម្រះវិសាមញ្ញ "ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពាឱ្យបានត្រឹមត្រូវចំពោះ ជនរងគ្រោះ និង សាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤, ១៥ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦៦ 999 UNTS 171។

31. ការងាររៀបចំរបស់ អ.វ.ត.ក ដែលជាមធ្យោបាយបន្ថែមសម្រាប់ការបកស្រាយតាមមាត្រា ៣២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា បានឆ្លុះបញ្ចាំងថា អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយមានជំនួយពីសហគមន៍អន្តរជាតិ ដើម្បីជំនុំជម្រះចារីនៃឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ដោយមានការផ្តល់សំណងចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះ។ ប្រវត្តិសាស្ត្ររបស់ខ្មែរក្រហមសង្កត់ធ្ងន់ទៅលើសារៈសំខាន់ចំពោះជនរងគ្រោះ និងសហគមន៍កម្ពុជា ក្នុងការថ្កោលទោសជាសាធារណៈដោយតុលាការមានសមត្ថកិច្ចចំពោះលើអំពើសាហាវយង់ឃ្នងនានា។ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានប្រជាជនយ៉ាងហោចណាស់ ១.៧ លាននាក់ បានស្លាប់ដោយសារការសម្លាប់ ការធ្វើទារុណកម្ម ភាពអត់ឃ្លាន និងពលកម្មដោយបង្ខំ ដែលកើតឡើងនៅក្នុងផែនការសមូហភាពរយៈពេលបួនឆ្នាំ ដែលមាន ការរំលោភសិទ្ធិមនុស្សដទៃផ្សេងទៀត ដូចជា ការបំបែកចេញពីក្រុមគ្រួសារ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការកេងប្រវ័ញ្ចលើកុមារ[37]។ បន្ថែមពីលើជនរងគ្រោះរាប់លាននាក់ ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីប្រទេសបានធ្លាក់ចូលទៅក្នុងរបបខ្មែរក្រហម មានប្រជាជនប្រមាណ ៦០០ ០០០ នាក់ បានរត់ភៀសខ្លួនពីប្រទេស[38] ដោយពួកគេភាគច្រើនបានទទួលរងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ ដោយមិនមានឧបាស្រ័យតាមផ្លូវតុលាការ។ ជនភៀសខ្លួនកម្ពុជាមកពីរបបខ្មែរក្រហម បានទៅតាំងទីលំនៅជាថ្មី នៅតាមប្រទេសមួយចំនួននៅទូទាំងពិភពលោក ដែលក្នុងនោះ រួមមាន សហរដ្ឋអាមេរិក (១៥២ ៧៥៨) វៀតណាម (១៥០ ០០០) បារាំង (៣៨៥៩៨) កាណាដា (២១ ៤៨៩) អូស្ត្រាលី (១៧ ៦០៥) ម៉ាឡេស៊ី (១០ ០០០) នូវែលហ្សេឡង់ (៥ ៩៩៥) និងស្វីស (១៧១៧)[39]។

32. ដោយទទួលស្គាល់ពីតម្រូវការយ៉ាងខ្លាំងក្នុងការធ្វើឱ្យមានគណនេយ្យភាព និងយុត្តិធម៌ សហនាយករដ្ឋមន្ត្រីនៅពេលនោះបានផ្ញើលិខិតទៅលោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ១៩៩៧ ស្នើសុំជំនួយ "សង្ឃឹមថា អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ អាច

---

[37] *ការណែនាំអំពី អ.វ.ត.ក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (n.d.), https://www.eccc.gov.kh/en/introduction-eccc។ សូមមើលផងដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) http://www.d.dccam.org/Projects/Genocide/DK_Book/DK_History--EN.pdf (ចូលមើលចុងក្រោយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩)។

[38] Stéphanie Nann, *Les Cambodgiens en France, entre l`image et la réalité*, MIGRATIONS SOCIÉTÉ 19, 147, 152 (ឆ្នាំ២០០៧)។

[39] តួលេខនៅក្នុងវង់ក្រចក បង្ហាញពីចំនួនសរុបនៃជនភៀសខ្លួននៅរបបខ្មែរក្រហម ដែលទៅតាំងទីលំនៅជាថ្មី នៅក្នុងប្រទេសនីមួយៗ។YUK WAH CHAN, DAVID HAINES, AND JONATHAN H.X. LEE, THE AGE OF ASIAN MIGRATION: CONTINUITY, DIVERSITY, AND SUSCEPTIBILITY, VOLUME 1 នៅត្រង់ ២៤៥ (ឆ្នាំ២០១៤)។

ជួយប្រជាជនកម្ពុជា ក្នុងការស្វែងរកការពិតអំពីរបបនេះ ហើយនាំយកអ្នកដែលទទួលខុសត្រូវមកជំនុំជម្រះ។ មានតែវិធីសាស្ត្រនេះទេ ទើបអាចបញ្ចប់ដោយពេញលេញ និងជាស្ថាពរចំពោះសោកនាដកម្មមួយនេះ"[40]។ ដោយសង្គ្រាមស៊ីវិលទើបតែបញ្ចប់នាពេលថ្មីៗ សហនាយករដ្ឋមន្ត្រីទទួលស្គាល់ថា "កម្ពុជាមិនមានធនធាន ឬជំនាញ ក្នុងការបំពេញនីតិវិធី ដែលមានសារៈសំខាន់ខ្លាំងបែបនេះ" ក្នុងការ "នាំយកមកជំនុំជម្រះអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"[41]។

33. នៅបណ្ដាឆ្នាំបន្ទាប់មក កម្ពុជា និងសហគមន៍អន្តរជាតិ បានសហការគាំទ្របង្កើតយន្តការតុលាការថ្មីមួយ។ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានផ្ដល់ការគាំទ្រដល់សហនាយករដ្ឋមន្ត្រី ដោយទ្រង់បានថ្លែងពីការគាំទ្រឱ្យមានតុលាការដែលមានជំនួយពីអន្តរជាតិ ដោយសារតែឧក្រិដ្ឋកម្មនៅកម្ពុជា "ពាក់ព័ន្ធដល់មនសិការនៃសហគមន៍ទូទាំងពិភពលោក"[42]។ ដូចគ្នានេះ ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិអំពីប្រទេសកម្ពុជា បានទទួលការគាំទ្រជាទូទៅនៅក្នុងបណ្ដាប្រជាជននានា "គណនេយ្យភាពគឺជាសេចក្ដីប្រកាសដំបូង និងសំខាន់បំផុត សម្រាប់ជនរងគ្រោះ និងសាច់ញាតិមិត្តភក្ដិជនរងគ្រោះកម្ពុជារាប់លាននាក់ ហើយយ៉ាងហោចណាស់ ក៏គួរមានការទទួលដឹងឮអំពីសម្រែករបស់ពួកគេ ដោយផ្ដល់ដល់អ្នកនៅរស់រានមានជីវិតនូវអារម្មណ៍ទទួលបានយុត្តិធម៌ និងការបិទបញ្ចប់អតីតកាលខ្លះៗ"[43]។ ក្រុមអ្នកជំនាញបានរាយការណ៍ថា "ចាប់ពីពេលពិភាក្សាជាមួយកម្ពុជា ទាំងនៅក្នុង និងក្រៅជួររដ្ឋាភិបាល យើងបានស្ដាប់ឮអំពីការទាមទារយ៉ាងច្បាស់លាស់ឱ្យមានការជំនុំជម្រះ។ អ្នកទាំងអស់គ្នានិយាយអំពីសារៈសំខាន់នៃយុត្តិធម៌សម្រាប់សន្តិភាព ស្ថិរភាព និងការបង្រួបបង្រួមជាតិ"[44]។ មិនមានប្រជាជនកម្ពុជាណាដែលត្រូវបានពិភាក្សានៅក្នុង

---

[40] សារលិខិត ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៩៧ របស់នាយករដ្ឋមន្ត្រីទីមួយ និងនាយករដ្ឋមន្ត្រីទីពីរកម្ពុជា ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ Doc. A/51/930 (ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧)។

[41] ដូចជើងទំព័រខាងលើ។

[42] អគ្គលេខាធិការអង្គការសហប្រជាជាតិ *របាយការណ៍ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានចេញផ្សាយអនុលោមតាមសេចក្ដីសម្រេចលេខ ៥២/១៣៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិ* U.N. Doc. A/53/850, ឧបសម្ព័ន្ធ កថាខណ្ឌ ៩៣ (ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩)។

[43] ដូចជើងទំព័រខាងលើ នៅត្រង់ ឧបសម្ព័ន្ធ កថាខណ្ឌ ២។

[44] ដូចជើងទំព័រខាងលើ នៅត្រង់ ឧបសម្ព័ន្ធ កថាខណ្ឌ ៩៤។

របាយការណ៍នោះ "លើកឡើងថា សន្តិភាព និងការជំនុំជម្រះ មិនអាចសម្រុះសម្រួលបាននោះទេ"[45]។

34. សម្រាប់តួនាទីរបស់អង្គការសហប្រជាជាតិ ពួកគេបានគាំទ្រ និងលើកទឹកចិត្ត ឲ្យមានក្របខណ្ឌយុត្តាធិការមួយ ដែលត្រូវមានលក្ខណៈលម្អិត។ នៅពេលផ្ញើលិខិតទៅមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ អគ្គលេខាធិការ កូហ្វី អាណាន់ បានថ្លែងឡើងថា "ការជំនុំជម្រះមេដឹកនាំយោធាខ្មែរក្រហមតែម្យ៉ាង ដោយទុកឲ្យមេដឹកនាំនយោបាយទាំងអស់រួចផុតពីទណ្ឌកម្ម នឹងមិនបម្រើដល់បុព្វហេតុយុត្តិធម៌ និងគណនេយ្យភាពឡើយ"[46]។ នៅក្នុងការស្រាវជ្រាវអំពីបទដ្ឋានយុត្តាធិការដែលត្រូវបានអនុម័តជាចុងក្រោយគឺថា មេដឹកនាំជាន់ខ្ពស់ និងអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ក្រុមអ្នកជំនាញបានសម្រេចថា "បុគ្គលមួយចំនួនដែលត្រូវជំនុំជម្រះ អាចស្ថិតក្នុងរង្វង់ពី ២០ ទៅ ៣០ នាក់"[47]។ ដូចគ្នានេះ ក្រុមដែលតស៊ូមតិសម្រាប់អ្វីដែលបានក្លាយជាធាតុផ្សំជាសារវ័ន្តនៃ អ.វ.ត.ក គឺ ការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការនីតិវិធី ព្រោះ "ការជំនុំជម្រះមេដឹកនាំខ្មែរក្រហមចាំបាច់ត្រូវមានការបង្ហាញថា មិនត្រឹមតែផ្តល់យុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានគេមើលឃើញថាបានផ្តល់យុត្តិធម៌ថែមទៀតផង"[48]។ ហេតុដូច្នេះ ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក ឆ្លុះបញ្ចាំងជាប្រចាំពីការអំពាវនាវយ៉ាងទូលំទូលាយឲ្យមានការព្យាបាល ការទទួលស្គាល់ និងការបង្រួបបង្រួម តាមរយៈការជំនុំជម្រះដើម្បីស្វែងរកយុត្តិធម៌អន្តរជាតិ។

### ii. ការអនុវត្តនាពេលក្រោយមក បន្ទាប់ពីបង្កើត អ.វ.ត.ក

35. ការអនុម័តទៅលើវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បន្ទាប់ពីបង្កើត អ.វ.ត.ក ដែលមកដល់ពេលនេះជាវិសោធនកម្មលើកទី ៩ ហើយនោះ អាចត្រូវបានប្រើជាការបង្ហាញពីការអនុវត្តនាពេលបន្ទាប់ នៅក្នុងអត្ថន័យនៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា។ វិធានផ្ទៃក្នុងទាំងអស់នេះបានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តក្នុងការអនុញ្ញាតឲ្យកិច្ចស៊ើបសួរ និងការជំនុំជម្រះបន្តទៅមុខ ក្នុងករណីមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ដែលសម្រេចផ្ទុយ ព្រមទាំងការទទួល

[45] ដូចដើងទំព័រខាងលើ នៅត្រង់ ឧបសម្ព័ន្ធ កថាខណ្ឌ ១០០។

[46] ដូចដើងទំព័រខាងលើ នៅត្រង់ទំព័រ ៣។

[47] ដូចដើងទំព័រខាងលើ កថាខណ្ឌ ១១០។

[48] ដូចដើងទំព័រខាងលើ នៅត្រង់ កថាខណ្ឌ ១៣៤។

ស្គាល់ថា បទប្បញ្ញត្តិ អ.វ.ត.ក គួរត្រូវបានបកស្រាយដើម្បីផ្តល់ការចូលរួមប្រកបដោយអត្ថន័យសម្រាប់ជនរងគ្រោះ។

36. ជាដំបូង បទប្បញ្ញត្តិនិតិវិធីជាច្រើននៅក្នុងវិធានផ្ទៃក្នុង បានឆ្លុះបញ្ចាំងអំពីគោលការណ៍ទូលាយ ដែលគាំទ្រដល់ការជំរុញកិច្ចដំណើរការនីតិវិធីតុលាការ ដែលជាសច្ចធារណ៍កំណត់។ ដូចដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធាន ៧២(២) នៃវិធានផ្ទៃក្នុង បានកំណត់ថា ក្នុងករណីមានការខ្វែងយោបល់គ្នា ចៅក្រមស៊ើបអង្កេតម្នាក់អាចលើកឡើងបញ្ហានេះជូនទៅអង្គបុរេជំនុំជម្រះដើម្បីពិនិត្យ[49]។ ប្រសិនបើអង្គបុរេជំនុំជម្រះនៅពេលបន្ទាប់មក មិនអាចចេញសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់បាន "សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រមានន័យថា ដីកា ឬកិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតម្នាក់ ត្រូវមានសុពលភាព"[50]។ សម្រាប់បណ្តឹងឧទ្ធរណ៍នៅមុនពេលជំនុំជម្រះដទៃទៀត វិធាន ៧៧ ដដែលតម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមាន ដើម្បីបញ្ឈប់ការបន្តជាក់ស្តែងនៃកិច្ចដំណើរការនីតិវិធី ដែលរងការជំទាស់នានា។ នៅក្នុងករណីដែលមិនមានសម្លេងភាគច្រើនលើសលប់តាមការតម្រូវ "ដីកា ឬកិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ... ត្រូវតម្កល់ទុកជាបានការ"[51]។ ប្រហែលគ្នានេះ ក្នុងករណីមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ដែលសម្រេចផ្ទុយពីនោះ វិធាន ៧៧ នៃវិធានផ្ទៃក្នុងចែងថា "ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត"[52]។

37. ទីពីរ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងអំពីគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក ដែលចែងថា ឯកសារស្នូលរបស់ អ.វ.ត.ក ចាំបាច់ត្រូវតែបកស្រាយ ដើម្បីការពារផលប្រយោជន៍ជនរងគ្រោះ

---

[49] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ៧២(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។

[50] ដូចជើងទំព័រខាងលើ នៅត្រង់វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[51] ដូចជើងទំព័រខាងលើ នៅត្រង់វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង។

[52] ដូចជើងទំព័រខាងលើ នៅត្រង់វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។

និងធានាថា សិទ្ធិរបស់ពួកគេ ត្រូវទទួលបានការគោរពនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល[53]។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ "កិច្ចព្រមព្រៀងបានចែងថា គោលការណ៍ជាសារវន្តមួយ ក្នុងការបង្កើត អ.វ.ត.ក គឺ "ការបង្រួបបង្រួមជាតិ""[54]។ គោលការណ៍នេះណែនាំដល់ចៅក្រម និងអង្គជំនុំជម្រះនៃ អ.វ.ត.ក ឲ្យស្វែងរកទាំងការពិតអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងយកចិត្តទុកដាក់ជាពិសេស ព្រមទាំងធានានូវការចូលរួមប្រកបដោយអត្ថន័យ សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ដែលជាផ្នែកមួយនៃការស្វែងរកការបង្រួបបង្រួមជាតិ[55]។ ដូចគ្នានេះ វិធាន ២៩ នៃវិធានផ្ទៃក្នុង បានកំណត់ប្រហែលគ្នាអំពីតម្រូវការសម្រាប់ អ.វ.ត.ក ក្នុងការពិចារណាទៅលើសិទ្ធិ និងតម្រូវការរបស់ជនរងគ្រោះ ដោយកំណត់អាណត្តិការងារថា អ.វ.ត.ក "ត្រូវធានាអំពីកិច្ចការពារជនរងគ្រោះ ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី" ហើយមន្ត្រីរបស់តុលាការ "ត្រូវគិតពិចារណាដល់សេចក្តីត្រូវការរបស់ជនរងគ្រោះ" នៅពេលបំពេញភារកិច្ចរបស់ពួកគេ[56]។ ដើម្បីសម្រេចបានគោលដៅទាំងអស់នេះ អ.វ.ត.ក បានផ្តល់នូវយន្តការពិសេសមួយសម្រាប់ការចូលរួមរបស់ជនរងគ្រោះ គឺបណ្តឹងរដ្ឋប្បវេណី ដែលមាន "គោលបំណងនៅចំពោះមុខ អ.វ.ត.ក ដើម្បី ... ទាមទារសំណងផ្លូវចិត្ត និងសមូហភាព"[57]។ ពាក្យពេចន៍នេះ នៅពេលពិនិត្យរួមគ្នា ក្លាយជាគោលការណ៍ណែនាំដល់ អ.វ.ត.ក ឲ្យយកចិត្តទុកដាក់ជាពិសេស និងធានាអំពីការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ និងសិទ្ធិរបស់ពួកគេក្នុងការស្វែងរកយុត្តិធម៌ ដែលជាផ្នែកមួយនៃការស្វែងរករួមរបស់ជាតិ សម្រាប់ការពិត និងការបង្រួបបង្រួមជាតិ។ ទោះជាយ៉ាងនេះក្តី បំណងប្រាថ្នាដែលបានលើកឡើងទាំងនេះ នឹងក្លាយជាឥតប្រយោជន៍ ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព បែរជាមិនអាចបន្តនីតិវិធីទៅដំណាក់កាលជំនុំជម្រះ ដោយសារតែការជាប់គាំងផ្នែកនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

---

[53] ដូចជើងទំព័រខាងលើ នៅត្រង់វិធាន ២១ នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក ("សំណុំរឿង ០០២) ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[54] ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ ៦១។

[55] ដូចជើងទំព័រខាងលើ។

[56] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៩(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។)

[57] ដូចជើងទំព័រខាងលើ វិធាន ២៣(១)(ខ) ថ្មី នៃវិធានផ្ទៃក្នុង។

**២. ច្បាប់កម្ពុជា រួមទាំងច្បាប់អន្តជាតិ ដែលបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានគាំទ្រការអនុញ្ញាតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានស្រាប់ ឲ្យបន្តនីតិវិធីទៅដំណាក់កាលជំនុំជម្រះ**

*ក. ច្បាប់កម្ពុជាគាំទ្រដល់យុត្តិធម៌សម្រាប់ជនរងគ្រោះ និងការបន្តកិច្ចដំណើរការនីតិវិធី ក្នុងករណីមិនមានការសម្រេចផ្ទុយ ដោយអាជ្ញាធរជាន់ខ្ពស់*

38. ច្បាប់ជាតិកម្ពុជា ដែលវិធានគ្រប់គ្រង អ.វ.ត.ក បានប្រើប្រាស់យ៉ាងច្រើននោះ គាំទ្រដល់យុត្តិធម៌សម្រាប់ជនរងគ្រោះ និងការបន្តកិច្ចដំណើរការនីតិវិធី ក្នុងពេលមិនមានការសម្រេចផ្ទុយ។ នៅក្នុងសុន្ទរកថាបើក ក្រមនីតិវិធីព្រហ្មទណ្ឌ ឯកឧត្តម អង្គវង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានថ្លែងថា ពួកយើងជឿជាក់ថា ក្រមនេះ នឹងក្លាយទៅជា "លិខិតុបករណ៍ដ៏សំខាន់" សម្រាប់លើកកម្ពស់ "ការទទួលបានយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា"[58]។ តាមពិតទៅ ការយោងទៅរកការទទួលបានយុត្តិធម៌ ស្ថិតនៅជួរចុងក្រោយនៃសុន្ទរកថាបើកនេះ ដូច្នេះហើយ គ្របដណ្តប់ទាំងស្រុង ទៅលើខ្លឹមសារនៃក្រមនេះ។

39. ខ្លឹមសារនៃក្រមនេះក៏គាំទ្រផងដែរដល់ការអនុញ្ញាតដល់ការជំរុញសំណុំរឿងរបស់ អោ អាន ទៅមុខ ជាពិសេសការចែងអំពីសច្ចធារណ៍នៃការបន្ត។ ឧទាហរណ៍ មាត្រា ២៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "កាលណាសភាស៊ើបសួរបានទទួលពាក្យបណ្តឹងសុំមោឃកម្ម ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្តីសម្រេចផ្ទុយពីនេះ របស់ប្រធានសភាស៊ើបសួរ"[59]។ ដូចគ្នានេះ មាត្រា ២៧៥ ចែងថា "ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ចំពោះដីកាណាមួយ ក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ អាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្តីសម្រេចផ្ទុយ របស់ប្រធានសភាស៊ើបសួរ"[60]។ មាត្រាទាំងអស់នេះបញ្ចូលគោលគំនិតតែមួយ ដែលមានផងដែរនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ក្នុងករណីស្ថាប័នជាន់ខ្ពស់ មិនបានផ្អាកកិច្ចដំណើរការនីតិវិធី ពេលនោះសច្ចធារណ៍គាំទ្រដល់ការបន្ត។

---

[58] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) សុន្ទរកថាឯកឧត្តម អង្គ វង្សវឌ្ឍនា។

[59] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៥៥។

[60] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៧៥។

*ខ. កាតព្វកិច្ចអន្តរជាតិ រួមទាំងភារកិច្ចជំនុំជម្រះ និងសិទ្ធិទទួលបានសំណងរបស់ជនរងគ្រោះ គឺជាផ្នែកនៃច្បាប់កម្ពុជា ហើយគាំទ្រដល់ការជំរុញដីកាបញ្ជូនរឿងទៅជំនុំជម្រះឲ្យបន្ត*

40. ច្បាប់កម្ពុជាបានរួមបញ្ចូលច្បាប់អន្តរជាតិ។ ហេតុដូច្នេះ ភារកិច្ចជំនុំជម្រះ និងសិទ្ធិទទួលបានសំណងរបស់ជនរងគ្រោះ ដែលមានចែងក្នុងសន្ធិសញ្ញា និងទំនៀមទម្លាប់អន្តរជាតិ គឺជាភារកិច្ចនិងសិទ្ធិតាមច្បាប់កម្ពុជា។ ដោយសារតែ អ.វ.ត.ក គឺជាស្ថាប័នកម្ពុជា ស្ថាប័ននេះត្រូវអនុវត្តកាតព្វកិច្ចទាំងនេះ[61]។

41. ច្បាប់អន្តរជាតិចងកាតព្វកិច្ចសម្រាប់កម្ពុជា។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានបញ្ចូលកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងប្រភពច្បាប់អន្តរជាតិ ទៅក្នុងច្បាប់ជាតិ[62]។ នៅក្នុងឆ្នាំ ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា បានសម្រេចថា ច្បាប់អន្តរជាតិដែលកម្ពុជាទទួលស្គាល់ តាមពិតទៅ គឺជាច្បាប់ជាធរមានរបស់ជាតិ ហើយចៅក្រមជាតិត្រូវពិចារណាទៅលើច្បាប់នោះ[63]។ បើទោះបីជាពិចារណាអំពីប្រភពបន្ថែមនៃច្បាប់ ក៏ច្បាប់អន្តរជាតិអនុវត្តជាមួយ និងជំរុញដល់វិធាននីតិវិធី និងនិយាមពាក់ព័ន្ធ ដែលមានចែងក្នុងច្បាប់ជាតិកម្ពុជា[64]។

42. ប្រភពច្បាប់អន្តរជាតិដែលចងកាតព្វកិច្ចចំពោះកម្ពុជា ដូចជា សន្ធិសញ្ញា ការអនុវត្តរបស់រដ្ឋ និងយុត្តិសាស្ត្រអន្តរជាតិ បានតម្រូវឲ្យរដ្ឋធ្វើការជំនុំជម្រះឧក្រិដ្ឋកម្ម ដែលមានស្ថានទម្ងន់ក្នុងកម្រិត មួយ។ សន្ធិសញ្ញាពហុភាគីដែលកម្ពុជាជាសមាជិក បានចែងនៅក្នុងនោះ ដោយផ្ទាល់ ឬដោយ

[61] ដោយឡែក អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា បានបញ្ជាក់អំពីភាពចាំបាច់ក្នុងការពិចារណាទៅលើ "វិធានពាក់ព័ន្ធនានានៃច្បាប់អន្តរជាតិជាធរមាន ស្តីពីទំនាក់ទំនងរវាងភាគីនានា" អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ដូចជើងទំព័រខាងលើ ២៥ មាត្រា ៣១(៣)(គ)។

[62] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣១ (បានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៨)។

[63] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧/កបធ (ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) (កម្ពុជា) ("ពាក្យ "ច្បាប់" ដូចដែលបានយោងពីខាងលើ សំដៅលើច្បាប់ជាតិ រួមទាំងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល ច្បាប់ទាំងអស់ដែលនៅជាធរមាន និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់រួចហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ")។

[64] មាស បូរ៉ា ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ៨១ (Peng Hor et al. eds. 2016) (លើកឡើងថា ច្បាប់អន្តរជាតិមានតួនាទីសមស្រប ជាជំនួយបន្ថែមដល់ច្បាប់ជាតិ ដែលពេលខ្លះអាចជំនួសច្បាប់ជាតិ ហើយពេលខ្លះទៀត អាចជាយុត្តិសាស្ត្រ ដោយអាស្រ័យទៅលើនិយាមដែលចោទជាបញ្ហា)។

ប្រយោល អំពីភារកិច្ចក្នុងការជំនុំជម្រះចារីនៃបទល្មើសធ្ងន់ធ្ងរ[65]។ ប្រភពច្បាប់ទន់ (soft law) និង តុលាការអន្តរជាតិ បានបញ្ជាក់អំពីការហាមឃាត់មិនឲ្យមាននិទណ្ឌភាព ចំពោះការរំលោភសិទ្ធិ

---

[65] សូមមើលជាទូទៅ Thoris Ingadottir រឿងក្តីសកម្មភាពប្រដាប់អាវុធ តុលាការយុត្តិធម៌អន្តរជាតិ ការឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចរបស់រដ្ឋ ដើម្បីស៊ើបអង្កេត និងជំនុំជម្រះចំពោះបុគ្គល ពីបទរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ 78 Nordic J. Int'l L. 581, 591-95 (2010) (រៀបរាប់អំពីកាតព្វកិច្ចជាអន្តរជាតិក្នុងការជំនុំជម្រះចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ)។ សូមមើលផងដែរ លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ បុព្វកថា ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ 2187 U.N.T.S. 90 (កម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២) ("គាំទ្រថា ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ដែលជាក្តីបារម្ភរបស់សហគមន៍អន្តរជាតិជារួម មិនអាចគេចចេញពីការផ្តន្ទាទោសបានឡើយ ហើយចាំបាច់ត្រូវធានាអំពីការជំនុំជម្រះប្រកបដោយប្រសិទ្ធភាព តាមរយៈមធ្យោបាយនៅកម្រិតជាតិ និងតាមរយៈការធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការជាអន្តរជាតិ")។ អនុសញ្ញាក្រុងហ្សឺណែវស្តីពីការកែលម្អលក្ខខណ្ឌសម្រាប់កងកម្លាំងដែលរងរបួស និងមានជំងឺនៅសមរភូមិ មាត្រា ៤៩ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ("ភាគីកិច្ចសន្យាជាន់ខ្ពស់នីមួយៗ ត្រូវមានកាតព្វកិច្ចស្វែងរកអ្នកដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្តការរំលោភបំពានយ៉ាងធ្ងន់ធ្ងរបែបនេះ [ដូចមានចែងក្នុងមាត្រា ៥០] ហើយត្រូវនាំយកជននោះមកជំនុំជម្រះនៅចំពោះមុខតុលាការ ដោយមិនគិតអំពីជាតិសាសន៍របស់ជននោះឡើយ") (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៥៨) ។ អនុសញ្ញាក្រុងហ្សឺណែវស្តីពីការកែលម្អលក្ខខណ្ឌសម្រាប់កងកម្លាំងដែលរងរបួស និងមានជំងឺ និងអ្នករងគ្រោះដោយកប៉ាលនៅសមុទ្រ មាត្រា ៥០ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ 75 U.N.T.S. 85 (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៥៨) (ដូចគ្នាទៅនឹងការរំលោភបំពាន នៅក្នុងមាត្រា ៥១)។ អនុសញ្ញាទីក្រុងហ្សឺណែវ (III) ស្តីពីការប្រព្រឹត្តិចំពោះឈ្លើយសឹក មាត្រា ១២៩ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ 75 U.N.T.S. 135 (ដូចគ្នាសម្រាប់ការរំលោភបំពាន នៅក្នុងមាត្រា ១៣០) (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៥៨) ។ អនុសញ្ញាទីក្រុងហ្សឺណែវ ស្តីពីការការពារជនស៊ីវិល ក្នុងគ្រាសង្គ្រាម មាត្រា ១៤៦ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ 75 U.N.T.S. 287 (ដូចគ្នាសម្រាប់ការរំលោភបំពាន នៅក្នុងមាត្រា ១៤៧) (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៥៨)។ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទណ្ឌកម្មសាហាវយង់ឃ្នង អមនុស្សធម៌ និងបន្ថាបបន្ថោកនានា មាត្រា ៥, ៧.១ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ 1465 U.N.T.S. 85 (មាត្រា ៥ "រដ្ឋជាភាគីនីមួយៗ ត្រូវចាត់វិធានការ ដែលអាចមានភាពចាំបាច់ ដើម្បីបង្កើតយុត្តាធិការ ទៅលើបទល្មើសដែលមានចែងនៅក្នុងមាត្រា ៤ នៅក្នុងករណីដូចខាងក្រោម៖ [រៀបរាប់ពីទំនាក់ទំនងជាតិ ឬដែនដី ជាមួយជនល្មើស បទល្មើស ឬជនរងគ្រោះ]។ (មាត្រា ៧.១៖ រដ្ឋជាភាគីនៅក្នុងដែនដី ដែលនៅក្រោមយុត្តាធិការរបស់ខ្លួន រកឃើញថា បុគ្គលម្នាក់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងមាត្រា ៤ ត្រូវបញ្ជូនរឿងក្តីទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីជំនុំជម្រះ ឬធ្វើបត្យាប័នបញ្ជូនបុគ្គលនោះ ក្នុងករណីដូចមានចែងក្នុងមាត្រា ៥") (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២)។ អនុសញ្ញាស្តីពីការទប់ស្កាត់ និងដាក់ទណ្ឌកម្ម ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា IV, VI ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ 78 U.N.T.S. 277 (មាត្រា IV "បុគ្គលដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើងទៃផ្សេងទៀត ដែលមានចែងក្នុងមាត្រា III ត្រូវផ្តន្ទាទោស ទោះបីជាបុគ្គលទាំងនោះ ជាមេដឹកនាំស្របតាមរដ្ឋធម្មនុញ្ញ ជាមន្ត្រីសាធារណៈ ឬបុគ្គលឯកជនក្តី") (មាត្រា IV "បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឬអំពើងទៃផ្សេងទៀត ដែលមានចែងក្នុងមាត្រា III ត្រូវទទួលការជំនុំជម្រះ ដោយតុលាការមានសមត្ថកិច្ចរបស់រដ្ឋ ដែលអំពើនោះត្រូវបានប្រព្រឹត្តឡើង នៅក្នុងដែនដីរបស់ខ្លួន ឬដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលអាចមានយុត្តាធិការ") (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ

មនុស្សធ្ងន់ធ្ងរ។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សបានចែងថា "ជនគ្រប់រូបមានសិទ្ធិទទួលបានសំណងប្រកបដោយប្រសិទ្ធភាព ដោយតុលាការមានសមត្ថកិច្ចជាតិ ចំពោះអំពើរំលោភបំពានទៅលើសិទ្ធិជាសារវន្តដែលខ្លួនទទួលបាន តាមរយៈរដ្ឋធម្មនុញ្ញឬច្បាប់"[66]។ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ បានកំណត់អំពីគោលការណ៍ណែនាំសម្រាប់ការកាពារសិទ្ធិទទួលបានសំណង ដែលគាំទ្រដល់ភារកិច្ចក្នុងការជំនុំជម្រះ នៅបីពេលផ្សេងៗគ្នា[67]។ ភារកិច្ចនេះត្រូវបានបញ្ជាក់គាំទ្រដោយរដ្ឋ នៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ[68] ហើយតុលាការយុត្តិធម៌អន្តរជាតិបានជំរុញដល់រដ្ឋឲ្យសហការជាមួយតុលាការព្រហ្មទណ្ឌ ហើយនាំខ្លួនចារីចូលទៅក្នុងកិច្ចដំណើរការនីតិវិធីជាតិ[69]។

---

១៩៥០)។ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ២(៣)(ក) ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦៦ 999 U.N.T.S. 171 ("រដ្ឋជាសមាជិកនៃកតិកាសញ្ញានេះ ត្រូវអនុវត្តដើម្បីធានាថា បុគ្គលណាម្នាក់ដែលសិទ្ធិដូចដែលមានចែងនៅក្នុងនេះ ត្រូវបានរំលោភបំពាន មានសិទ្ធិទទួលបានសំណងប្រកបដោយប្រសិទ្ធភាព ដោយមិនគិតថាការរំលោភបំពាននោះ ត្រូវបានប្រព្រឹត្តដោយបុគ្គល ដែលបំពេញការងារក្នុងសមត្ថកិច្ចផ្លូវការ ឬយ៉ាងណានោះទេ") (កម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២)។

[66] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៨ G.A. Res. 217 (III) (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨)

[67] គោលការណ៍ណែនាំ និងគោលការណ៍ជាមូលដ្ឋាន ស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណង សម្រាប់ជនរងគ្រោះដោយការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ៣(ខ) ៤ និង ២២(ច) G.A. Res. 60/147, UN Doc. A/RES/60/147 (ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦)។

[68] សូមមើល *ជាឧទាហរណ៍* បុគ្គលិកទូត និងស្ថានកុងស៊ុល សហរដ្ឋអាមេរិកនៅទីក្រុង Tehran (អាមេរិក តទល់នឹង អ៊ីរ៉ង់) សាលក្រម 1980 I.C.J. Rep. 3, កថាខណ្ឌ ៨ (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៨០) (បង្ហាញពីការអះអាងរបស់សហរដ្ឋអាមេរិកដែលថា អ៊ីរ៉ង់ គួរតែ "បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការជំនុំជម្រះ នូវបណ្តាជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើបរិវេណ និងបុគ្គលិកស្ថានទូត សហរដ្ឋអាមេរិក និងទៅលើបរិវេណ និងបុគ្គល ស្ថានកុងស៊ុលរបស់អាមេរិក")។ សកម្មភាពប្រដាប់អាវុធទៅលើទឹកដីប្រទេសកុងហ្គោ (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ តទល់នឹង អ៊ូហ្គាន់ដា) សាលក្រម 2005 I.C.J. Rep. 168 កថាខណ្ឌ ២៥ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥) (បង្ហាញពីការអះអាងរបស់កុងហ្គោដែលថា អ៊ូហ្គាន់ដាបានរំលោភបំពានទៅលើគោលការណ៍ច្បាប់អន្តរជាតិ តាមរយៈ "ការមិនដាក់ទណ្ឌកម្មចំពោះបុគ្គលដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន ឬស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ដែលបានចូលរួមក្នុងការរំលោភបំពានសិទ្ធិមនុស្ស")។ បញ្ហាទាក់ទងកាតព្វកិច្ចជំនុំជម្រះ ឬធ្វើបត្យាប័ន (Belg. v. Sen.) សាលក្រម 2012 I.C.J. Rep. 422 កថាខណ្ឌ ៧១ (ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២) ("បែលហ្ស៊ិកបានស្នើដល់តុលាការឲ្យជំនុំជម្រះ និងប្រកាសថា សេណេហ្គាល់មានកាតព្វកិច្ចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ [ប្រឆាំងអ្នកធ្វើទារុណកម្មដែលរងការចោទប្រកាន់] ... ហើយមិនបានធ្វើបត្យាប័នបុគ្គលនេះទៅបែលហ្ស៊ិក")។

[69] សកម្មភាពប្រដាប់អាវុធទៅលើទឹកដីប្រទេសកុងហ្គោ (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ តទល់នឹង អ៊ូហ្គាន់ដា) សាលក្រម 2005 I.C.J. Rep. 168, កថាខណ្ឌ ២៨០ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥) (សម្រេចថា អ៊ូហ្គាន់ដា "ដោយសារតែមិនបានចាត់

43. ប្រភពអន្តរជាតិទាំងអស់ដែលបានលើកឡើងខាងលើ បានបង្ហាញថា កម្ពុជាជាប់កាតព្វកិច្ចតាមច្បាប់ជាតិ ដោយសន្ធិសញ្ញា និងទំនៀមទម្លាប់ ក្នុងការជំនុំជម្រះជនទាំងឡាយណា ដែលត្រូវបានចោទប្រកាន់ពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ដូច្នេះ ការបញ្ជូនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) អោ អាន របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅអង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែស្របតាមការបកស្រាយកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ផ្អែកតាមច្បាប់អន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំពេញតាមកាតព្វកិច្ចយ៉ាងម៉ឺងម៉ាត់របស់កម្ពុជាក្នុងការជំនុំជម្រះតាមច្បាប់ជាតិរបស់កម្ពុជា។

44. ក្រៅពីការកំណត់អំពីភារកិច្ចរបស់កម្ពុជាក្នុងការជំនុំជម្រះជនល្មើសទៅលើសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ច្បាប់អន្តរជាតិក៏កំណត់អំពីសិទ្ធិទទួលបានសំណងរបស់ជនរងគ្រោះដែរ។ សិទ្ធិនេះរួមបញ្ចូលទាំងការចូលរួមក្នុងការជំនុំជម្រះជនទាំងឡាយណា ដែលទទួលខុសត្រូវចំពោះព្យសនកម្មរបស់ពួកគាត់ និងលទ្ធភាពក្នុងការទាមទារសំណង។ នៅពេលដែលសំណុំរឿងត្រូវបានជាប់គាំង នៅក្នុងភាពមិនប្រាកដប្រជាផ្នែកនីតិវិធី សំណងទាំងអស់នេះស្ថិតនៅឆ្ងាយផុតពីដៃ។

45. សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់ ផ្តល់ដល់ជនរងគ្រោះនូវសិទ្ធិទទួលបានសំណងប្រកបដោយប្រសិទ្ធភាព។ សិទ្ធិនេះគឺជាកម្មវត្ថុនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលផ្អែកលើបទប្បញ្ញត្តិដែលមាននៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា ៨) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា២) អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (មាត្រា៦) អនុសញ្ញាប្រឆាំងនឹងការធ្វើ

---

វិធានការចំពោះការគោរពសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ នៅក្នុងស្រុក Ituri បានរំលោភបំពាន់ទៅលើកាតព្វកិច្ចរបស់ខ្លួន")។ ការអនុវត្តអនុសញ្ញាស្តីពីការហាមឃាត់ និងដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (Bosnia និង Herzegovina តទល់នឹង Serbia និង Montenegro) សាលក្រម 2007 I.C.J. Rep. 43 កថាខណ្ឌ ៤៧១(៦) (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧) (សម្រេចថា ស៊ែបត្រូវទទួលខុសត្រូវ តាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ចំពោះការមិនសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី)។ បញ្ហាទាក់ទងនឹងបញ្ហាទាក់ទងកាតព្វកិច្ចជំនុំជម្រះ ឬធ្វើបត្យាប័ន (Belgium v. Senegal) សាលក្រម 2012 I.C.J. Rep. 422 កថាខណ្ឌ ១២២ (ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២) (សម្រេចថាសាធារណៈរដ្ឋសេណេហ្គាល់ បានបំពានទៅលើកាតព្វកិច្ចរបស់ខ្លួន "ដោយមិនបានស៊ើបសួរបឋមភ្លាមៗ ទៅលើអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត")។

ទារុណកម្ម (មាត្រា១៤) និងលក្ខន្តិកៈទីក្រុងរ៉ូម (មាត្រា ៦៨ និង៧៥)[70]។ សេចក្ដីសម្រេចនោះបាន អះអាងថា ជនរងគ្រោះដោយឧក្រិដ្ឋកម្មធ្ងន់ធ្ងរ មានសិទ្ធិ "ទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព សំណងឆាប់រហ័ស ដោយប្រសិទ្ធភាព និងគ្រប់គ្រាន់ ចំពោះព្យសកម្មដែលបានទទួលរង និងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងការរំលោភបំពាន និងយន្តការសំណង"[71]។

46. អ.វ.ត.ក គាំទ្រសិទ្ធិទាំងអស់នេះនៅក្នុងយន្តការនីតិវិធីរបស់ខ្លួន ដូចជា ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈវិធាន ២៣ នៃវិធានផ្ទៃក្នុង។ គោលបំណងទាំងអស់នេះ ដែលរួមទាំងសិទ្ធិទទួលបានសំណងតាមផ្លូវច្បាប់អន្តរជាតិ អាចបំពេញទៅបាន ជាក់ស្ដែង តែក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព ត្រូវបានអនុញ្ញាតឱ្យបន្តទៅដំណាក់កាលជំនុំជម្រះ ដែលនៅដំណាក់នោះ ចៅក្រមអាចធ្វើសេចក្ដីសម្រេចផ្នែកអង្គហេតុ និងអង្គច្បាប់ ដើម្បីកំណត់ពីការទទួលខុសត្រូវរបស់ជនជាប់ចោទនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ ព្រមទាំងសំណងផ្លូវចិត្ត និងសមូហភាពនានា ដែលត្រូវផ្ដល់ជូនដើមបណ្ដឹងរដ្ឋប្បវេណី។

## ខ. ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាភាគី នៃកិច្ចដំណើរការនីតិវិធី ហើយចាំបាច់ត្រូវគោរពដល់សិទ្ធិរបស់ពួកគាត់

47. ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាភាគីនៃកិច្ចដំណើរការនីតិវិធី[72]។ វិធាន ២៣ស្ទួន(២) នៃវិធានផ្ទៃក្នុងចែងថា "លើកលែង និងលុះត្រា តែពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចអនុវត្តសិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណីបាន"[73]។

48. មាត្រា ១២(២) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក បានចែងថា៖

---

[70] គោលការណ៍ណែនាំ និងគោលការណ៍ជាមូលដ្ឋាន ស្ដីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណង សម្រាប់ជនរងគ្រោះដោយការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ បុព្វកថា G.A. Res. 60/147, UN Doc. A/RES/60/147 (ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦)។

[71] ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ ១១។

[72] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) សទ្ទានុក្រម (ធ្វើវិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥) (កំណត់និយមន័យ "ភាគី" រួមបញ្ចូលទាំងសហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី)។

[73] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) (ធ្វើវិសោធនកម្មថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។

អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។ ក្នុងផលប្រយោជន៍ធានាឱ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់។ ការលើកលែងមិនឱ្យចូលរួមស្តាប់ការជំនុំជម្រះក្តីនេះ តាមមាត្រា១៤ នៃអនុសញ្ញាអាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណា ដែលការផ្សព្វផ្សាយចេញទៅនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌[74]។

49. មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើជាសាធារណៈ និងបើកចំហសម្រាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌[75]។

50. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា៖

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី ប្រកបដោយតម្លាភាព ដោយគិតដល់

[74] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១២(២)។

[75] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៤ ថ្មី។

លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង ។ ក្នុងបរិបទនេះ៖

…

គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី[76]។

51. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សិទ្ធិដែលមានចែងក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវអនុវត្តចំពោះដើមបណ្ដឹងរដ្ឋប្បវេណី[77]។ វិធាន ១៤(១) ចែងថា "បុគ្គលរាល់រូបមានភាពស្មើគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ។ នៅក្នុងការសម្រេចអំពីបទចោទព្រហ្មទណ្ឌណាមួយប្រឆាំងរូបគាត់ ឬអំពីសិទ្ធិ និងកាតព្វកិច្ចរបស់គាត់ ក្នុងបណ្ដឹងតាមផ្លូវច្បាប់ បុគ្គលរាល់រូបត្រូវទទួលបានសិទ្ធិមានសវនាការជាសាធារណៈ និងប្រកបដោយយុត្តិធម៌ ដោយអង្គជំនុំជម្រះដែលមានសមត្ថភាព ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់"[78]។

**១. សិទ្ធិជាសារវ័ន្តរបស់ជនរងគ្រោះ មានចែងនៅក្នុងឯកសារគោល អ.វ.ត.ក និងច្បាប់អន្តរជាតិ ចាំបាច់ត្រូវតែជាគោលការណ៍ណែនាំសម្រាប់កិច្ចដំណើរការនីតិវិធីទាំងអស់នេះ**

52. បើទោះបីជាមានតម្រូវការច្បាស់លាស់ក្នុងការផ្ទេរដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងជាមូលដ្ឋាននៃសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូងក្ដី ប៉ុន្តែផ្នែកគ្រប់គ្រងតុលាការមិនបានអនុវត្តការផ្ទេរនេះឡើយ។ ជាលទ្ធផល សំណុំរឿង០០៤/២ ត្រូវជាប់គាំងផ្នែកនីតិវិធីរវាង

[76] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១(១) (ធ្វើវិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។

[77] សំណុំរឿង ០០២ ឯកសារ F26/2/2 សេចក្ដីសម្រេចលើសំណើ សុំបន្ថែមពេលវេលារបស់ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5 កថាខណ្ឌ ៧ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ (ទទួលស្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណី "ទទួលបានសិទ្ធិក្នុងការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ ដូចមានចែងក្នុងមាត្រា ១៤(១)" និង "មានតួនាទីជាក់លាក់ និងមានកម្រិត នៅក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក")។

[78] កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ លេខ 999 U.N.T.S. 171។

ការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ដែលបានបណ្ដាល និងបន្តបណ្ដាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរចំពោះសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

53. ការគោរពសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី គឺជាធាតុផ្សំយ៉ាងសំខាន់សម្រាប់ការបង្រួបបង្រួមជាតិ ជាគោលដៅមួយដែលបានកំណត់ថាជា "គោលការណ៍ជាសារវ័ន្តមួយក្នុងការបង្កើត អ.វ.ត.ក"[79]។ នៅក្នុងសំណុំរឿង ០០២/០២ តុលាការនេះបានទទួលស្គាល់ថា គោលការណ៍បង្រួបបង្រួមជាតិ "បង្ហាញដល់ចៅក្រម ក៏ដូចជា អង្គជំនុំជម្រះ នៅ អ.វ.ត.ក ឱ្យស្វែងរកការពិតស្ដីពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ជាពិសេស និងការធានាថាមានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ"[80]។ ទោះបីជាសំណុំរឿងត្រូវបានអនុញ្ញាតឱ្យបន្តទៅជំនុំជម្រះឬអត់ ក៏បានជះឥទ្ធិពលជាសារវ័ន្តចំពោះសិទ្ធិ និងផលប្រយោជន៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើសំណុំរឿងមិនបន្តសិទ្ធិរបស់ពួកគាត់នៅចំពោះមុខ អ.វ.ត.ក ត្រូវបានរំលត់ រួមទាំងសិទ្ធិចូលរួមក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបន្តទៅមុខ និងទទួលបានតំណាងសម្រាប់ផលប្រយោជន៍ផ្លូវច្បាប់របស់ពួកគាត់ សិទ្ធិទទួលបានសេចក្ដីសម្រេចតាមផ្លូវតុលាការ ព្រមទាំងសិទ្ធិទទួលបានសំណងចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង ប្រសិនបើជនជាប់ចោទត្រូវបានផ្ដន្ទាទោស។ ដើមបណ្ដឹងរដ្ឋប្បវេណីចាំបាច់ត្រូវទទួលបានសិទ្ធិចូលរួមសវនាការអំពីបញ្ហាដែលអាចរំលត់ដល់សិទ្ធិក្នុងការចូលរួមរបស់ពួកគាត់។

54. វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងកំណត់បន្ថែមអំពីគោលការណ៍ជាសារវ័ន្តរបស់ អ.វ.ត.ក រួមទាំងឯកសារគោលរបស់ អ.វ.ត.ក ដែលចាំបាច់ត្រូវបកស្រាយ "ការពារផលប្រយោជន៍" របស់ជនរងគ្រោះ និងដើម្បីធានាថាសិទ្ធិរបស់ពួកគាត់ ត្រូវបានគោរពនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[81]។ ដូចគ្នានេះដែរ វិធាន ២៩ នៃវិធានផ្ទៃក្នុង ចែងថា អ.វ.ត.ក "ត្រូវធានាអំពីកិច្ចការពារដល់

[79] សំណុំរឿង ០០២ ឯកសារ D404/2/4, សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៥ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។

[80] *ដូចជើងទំព័រខាងលើ*។

[81] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ (ធ្វើវិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។ សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា

ជនរងគ្រោះ...ដែលមកបង្ហាញខ្លួន" ហើយមន្ត្រីតុលាការ "ត្រូវគិតពិចារណាដល់សេចក្តីត្រូវការរបស់ជនរងគ្រោះ" នៅពេលបំពេញតួនាទីរបស់ខ្លួន[82]។ ដោយអនុលោមតាមគោលបំណងទាំងអស់នេះ អ.វ.ត.ក បានផ្តល់យន្តការពិសេសសម្រាប់ការចូលរួមរបស់ជនរងគ្រោះ គឺបណ្តឹងរដ្ឋប្បវេណី[83]។ ចំណុចនេះត្រូវបានថ្លែងគាំទ្រដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលដកស្រង់សិទ្ធិជាសារវ័ន្ត ដែលមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង នៅក្នុងអនុស្សរណៈថ្ងៃទី១២ ខែមីនា របស់ពួកគាត់ ដោយរម្លឹកថា "គ្មានសិទ្ធិណាមួយត្រូវបានរក្សាទុកឡើយ ប្រសិនបើអង្គបុរេជំនុំជម្រះមិនបញ្ជាក់អំពីលទ្ធភាពសម្រាប់ភាគីនានាអាចទទួលបានចៅក្រមដែលមានសមត្ថកិច្ច គឺអង្គជំនុំជម្រះសាលាដំបូង"[84]។

---

របស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦១ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។

[82] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៩ (ធ្វើវិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។

[83] សំណុំរឿង ០០២ ឯកសារ **D404/2/4**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៩៦ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៣(១)(ខ) ស្ទួនបី (ធ្វើវិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។

[84] អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការជូនដំណឹងអំពី សេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។ សូមមើលផងដែរ ឯកសារភ្ជាប់លេខ ៦ នៃសំណុំរឿង ០០៤/២ ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ឯកសារ **F28** សាលដីកា កថាខណ្ឌ ៦៦១ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាសំណងផ្លូវចិត្ត និងសមូហភាពមិនអាចផ្តល់ សំណងពេញលេញដល់ជនរងគ្រោះ ពីការរំលោភសិទ្ធិមនុស្សខាងរូបកាយ ឬខាងសេដ្ឋកិច្ចក្តី ក៏គោលបំណងនៃសំណងទូទៅផ្សេងទៀត ត្រូវបានបំពេញនៅចំពោះមុខ អ.វ.ត.ក ក្នុងកម្រិតដែលអាចឆ្លើយតបទៅនឹង "ការរំលោភបំពានខាងចិត្តសាស្ត្រ ផ្លូវចិត្ត និងនិមិត្តរូប"។ ករណីនេះអាចសម្រេចបានតាមរយៈ "ការផ្ទៀងផ្ទាត់អង្គហេតុ និងការបង្ហាញការពិតពេញលេញជាសាធារណៈ" ដូចដែលលើកឡើងដោយសំអាងហេតុ របស់អង្គជំនុំជម្រះនានា **តាមរយៈការចូលរួមរបស់ជនរងគ្រោះ ក្នុងកិច្ចដំណើរការនីតិវិធី** និងការទទួលស្គាល់ជាបុគ្គលនៅក្នុងសាលក្រម និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលបង្ហាញនូវការទទួលស្គាល់ជាសាធារណៈ នូវការឈឺចាប់របស់ពួកគាត់...") (ដោយគូសបញ្ជាក់បន្ថែម")។

55. សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏មានចែងផងដែរពីកាតព្វកិច្ចការពារជនរងគ្រោះ និងផ្តល់សិទ្ធិដល់ជនរងគ្រោះ រួមទាំងសិទ្ធិទទួលបានសំណង និងទទួលបានយុត្តិធម៌។ សិទ្ធិរបស់ជនរងគ្រោះ គឺជាកម្មវត្ថុនៃសេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ ដែលអះអាងថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរមានសិទ្ធិ "ទទួលបានយុត្តិធម៌ស្មើភាព និងប្រកបដោយប្រសិទ្ធិភាព សំណងភ្លាមៗ ប្រកបដោយប្រសិទ្ធភាព និងសមស្រប ចំពោះព្យសនកម្មដែលបានទទួល និងសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងការរំលោភបំពាន និងយន្តការផ្តល់សំណង"[85]។ តុលាការ និងសន្ធិសញ្ញាអន្តរជាតិដទៃទៀត រួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ថា "សិទ្ធិជាសារ វ័ន្តក្នុងការទទួលបានសំណង និងការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលកំពុងបន្ត "គឺជាចំណុចស្នូលនៃសិទ្ធិរបស់ជនរងគ្រោះ"[86]។

56. នៅពេលបកស្រាយរួមគ្នា ពាក្យពេចន៍ទាំងនេះតម្រូវឱ្យ អ.វ.ត.ក មានការប្រុងប្រយ័ត្ន ជាពិសេសដើម្បីធានាពីការចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រកបដោយអត្ថន័យ សម្រាប់ជនរងគ្រោះ និង

---

[85] គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១១ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ U.N.G.A. Res. 60/147។

[86] សេចក្តីសម្រេចលើការចូលរួម របស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធស្ថានភាពនៅក្នុងសាធារណៈរដ្ឋកេនយ៉ា លេខ ICC-01/09-24 អង្គបុរេជំនុំជម្រះ II កថាខណ្ឌ ៥ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១០។ សូមមើលផងដែរ លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦៨, ៧៥ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨ លេខ 2187 U.N.T.S. 90។ អនុសញ្ញាអាមេរិក ស្តីពីសិទ្ធិមនុស្ស មាត្រា ២៥(១) ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ លេខ 1144 U.N.T.S.123 ("បុគ្គលរាល់រូបមានសិទ្ធិទទួលបាន ឧបាស្រ័យធម្មតានិងភ្លាមៗ ឬឧបាស្រ័យមានប្រសិទ្ធិភាពដទៃផ្សេងទៀត មានសិទ្ធិទទួលបានតុលាការ ឬអង្គជំនុំជម្រះដែលមានសមត្ថកិច្ច ដើម្បីការពារចំពោះសកម្មភាព ដែលរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្តរបស់ពួកគាត់ ដូចបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់រដ្ឋ ដែលពាក់ព័ន្ធ ឬដែលទទួលស្គាល់ដោយសន្ធិសញ្ញាមួយនេះ...")។ ពិធីសារនៃធម្មនុញ្ញអាហ្វ្រិក ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនលើការបង្កើតតុលាការអាហ្វ្រិក សម្រាប់សិទ្ធិមនុស្ស និងសិទ្ធិប្រជាជន មាត្រា ២៧(១) ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៨ ឯកសារ OAU លេខ OAU/LEG/MIN/AFCHPR/PROT.1 កែលើកកទី ២ (ឆ្នាំ ១៩៩៧) ("ប្រសិនបើតុលាការរកឃើញថា មានការរំលោភបំពានទៅលើសិទ្ធិមនុស្ស ឬសិទ្ធិប្រជាជន តុលាការត្រូវចេញដីកាសម្រេចសមស្រប ដើម្បីផ្តល់ឧបាស្រ័យចំពោះការរំលោភបំពាននេះ រួមទាំងការទូទាត់នូវសំណង ឬការបង់សងសមស្រប។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៨ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ លេខ G.A. Res. 217A (III), ឯកសារ អ.ស.ប A/810 នៅទំព័រ ៧១។កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ លេខ 999 U.N.T.S. 171។ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការធ្វើទារុណកម្ម ឬអំពើអមនុស្សធម៌ ឬបន្ទាប់បន្ថោកយ៉ាងសាហាវយង់ឃ្នងនានា មាត្រា ១៤ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ លេខ 1465 U.N.T.S. 85។

ការពារសិទ្ធិរបស់ពួកគាត់ ក្នុងការស្វែងរកយុត្តិធម៌ជាផ្នែកមួយនៃការព្យាយាមជារួមរបស់ជាតិក្នុងការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ។ គោលការណ៍ជាសារវន្តទាំងនេះ ចាំបាច់ត្រូវជាគោលការណ៍ណែនាំចំពោះគ្រប់ភាគីទាំងអស់ នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ រួមទាំងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនាពេលបច្ចុប្បន្ន។

**២. សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមសវនាការ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិទទួលបានសច្ចភាពគតិយុត្តិ និងសិទ្ធិទទួលបានការការពារ ចំពោះកិត្តិយស និងសុខុមាលភាព ចាំបាច់ត្រូវទទួលបានការគោរពនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក**

57. ភាពមិនប្រាកដប្រជា ដែលនៅតែបន្ត ជុំវិញស្ថានភាពនៃសំណុំរឿង ០០៤/២ រំលោភបំពានទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យ និងរារាំងដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រកបដោយអត្ថន័យ នៅក្នុងកិច្ចដំណើរការនីតិវិធី។ ភាគី និងស្ថាប័នទាំងអស់របស់ អ.វ.ត.ក ចាំបាច់ត្រូវអនុវត្តក្នុងលក្ខណៈមួយ ដែលការពារដល់កិត្តិយស និងសុខុមាលភាពរបស់ជនរងគ្រោះ និងធានាថា សិទ្ធិរបស់ជនរងគ្រោះ ត្រូវទទួលបានការគោរព។

*ក. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ តម្រូវឱ្យតុលាការផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវសច្ចភាពផ្លូវច្បាប់ និងព័ត៌មានមានតម្លាភាពច្បាស់លាស់ និងទាន់ពេលវេលា អំពីស្ថានភាពនៃសំណុំរឿង ០០៤/២*

58. ភាគីទាំងអស់ រួមទាំងជនរងគ្រោះ មានសិទ្ធិទទួលបានតម្លាភាព និងសច្ចភាពផ្លូវច្បាប់ នៅរាល់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឯកសារគោលរបស់ អ.វ.ត.ក ចាំបាច់ត្រូវបកស្រាយដើម្បី "ធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"[87]។ នៅក្នុងតុលាការមួយនេះ និងតុលាការដទៃទៀត គោលការណ៍តម្លាភាព និងសច្ចភាពផ្លូវច្បាប់ តម្រូវថា តុលាការត្រូវចេញសេចក្តីសម្រេចដោយមានសំអាងហេតុ នៅក្នុងបញ្ហាដែលស្ថិត

[87] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

នៅចំពោះមុខខ្លួន[88]។ តាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ព្រហ្មទណ្ឌ តម្លាភាព និងសច្ចភាពផ្លូវច្បាប់ក៏គ្របដណ្តប់ផងដែរចំពោះកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពី "វិសាលភាព ពេលវេលា និងការវិវឌ្ឍន៍នៃកិច្ចដំណើរការនីតិវិធី... ជាពិសេសនៅពេលដែលពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ" និង "ជៀសវាងការពន្យារពេលមិនចាំបាច់ នៅក្នុងការសម្រេចសេចក្តីលើរឿងក្តី"[89]។

59. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ បានរម្លឹកថា សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវចេញសេចក្តីសម្រេចដោយមានសំអាងហេតុ លើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគោរពដល់គោលការណ៍ជាមូលដ្ឋាននៃនីត្យានុកូលភាព រួមទាំងតម្លាភាព និងសច្ចភាពផ្លូវ

---

[88] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៧ -៣៨ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ ICTY បានសម្រេចថាសិទ្ធិទទួលបាន សេចក្តីសម្រេចដោយមានសំអាងហេតុ គឺជាធាតុផ្សំមួយនៃសិទ្ធិ ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងថា ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេច ដោយមានសំអាងហេតុតែមួយគត់ ដែលអាចមានការត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍ ប្រកបដោយភាពត្រឹមត្រូវ សូមមើល *រដ្ឋអាជ្ញា តទល់នឹង Momir Nikolic* សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងការផ្តន្ទាទោស អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៩៦ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ សំណុំរឿងលេខ IT-02-60/1-A។ អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY បានសម្រេចថា ""ជាអប្បបរមាអង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវផ្តល់សំអាងហេតុ ដើម្បីគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះទាក់ទងការពិចារណាលើអង្គសេចក្តី ពាក់ព័ន្ធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ"។ *រដ្ឋអាជ្ញា តទល់នឹង Milutinovic* និងអ្នកដទៃទៀត សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហំ ប្រឆាំងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតដោះលែង Nebojsa Pavkovic ជាបណ្តោះអាសន្ន អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ១១ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥ សំណុំរឿងលេខ IT-05-87-AR65.1។ សូមមើលផងដែរ *រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-774 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ១ ដែលមានចំណងជើងថា "សេចក្តីសម្រេចលើកទីពីរ លើសំណើរបស់រដ្ឋអាជ្ញា និងសំណើកែសម្រួល សុំកោសលប់ អនុលោមតាមវិធាន ៨១" អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣០ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ (កត់សម្គាល់ថា "មានតែផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចដោយមានសំអាងហេតុប៉ុណ្ណោះ ដែលអាចមានការត្រួតពិនិត្យ លើបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវ")។

[89] សេចក្តីប្រកាសលើគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច កថាខណ្ឌ ៦(ក),(ង) ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ U.N.G.A. Res. 40/34 ឧបសម្ព័ន្ធ ក.១។ សូមមើលផងដែរ គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១៤ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ U.N.G.A. Res. 60/147។

ច្បាប់[90]។ នៅក្នុង*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* អង្គបុរេជំនុំជម្រះបានទទួលស្គាល់ជាថ្មីម្តងទៀតពីសារៈសំខាន់នៃសច្ចភាពផ្លូវច្បាប់ ថាជា "សសរស្តម្ភមូលដ្ឋាននៃច្បាប់" មួយ[91]។ អង្គជំនុំជម្រះកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានធានានូវគោលការណ៍សច្ចភាពផ្លូវច្បាប់ តាមរយៈនីតិវិធី "ដោះស្រាយជាស្ថាពរចំពោះ ការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី"[92]។ អង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់បានសម្រេចថា ការចេញដីកាដំណោះស្រាយដាច់ពីគ្នា បង្កើតបានជា "ការមាក់ងាយដល់គោលការណ៍សច្ចភាពគតិយុត្តិជាមូលដ្ឋាន"[93] ហើយបង្កើតបានជា "ស្ថានភាពគតិយុត្តិដែលមិនធ្លាប់មាន" ដែលរំលោភបំពានទៅលើគោលការណ៍នានារបស់ អ.វ.ត.ក[94]។

60. ការចេញសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ មិនបានផ្តល់សច្ចភាពផ្លូវច្បាប់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ទោះបីជាក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលតម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ គួរបន្តទៅជំនុំជម្រះ ពេលមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ដែលសម្រេចផ្សេងពីនេះក្តី ដូចបានរៀបរាប់ខាងលើ ការជំទាស់ចំពោះការណែនាំពីចៅក្រមជាតិ និងចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះ ចំពោះមន្ត្រីទទួលបន្ទុកសំណុំរឿង បានបណ្តាលឲ្យមានការជាប់គាំងផ្នែកនីតិវិធី និងភាពបរាជ័យ ក្នុងការផ្ទេរសំណុំរឿង ០០៤/

---

[90] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៧-៣៨ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។

[91] សំណុំរឿង ០០៤/២ ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៨, ៩៥, ២០៥ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[92] សំណុំរឿង ០០៤/២ ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១១ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[93] សំណុំរឿង ០០៤/២ ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[94] សំណុំរឿង ០០៤/២ ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១០១ -១២៤ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

២ ទៅអង្គជំនុំជម្រះសាលាដំបូង ធ្វើឱ្យកិច្ចដំណើរការនីតិវិធីជាប់គាំងដោយប្រសិទ្ធភាព ដោយមិនមានដំណើរការច្បាស់លាស់ណាមួយសម្រាប់ដោះស្រាយភាពជាប់គាំងនេះ។

61. តាំងពីពេលដែល*សេចក្ដីពិចារណា*ត្រូវបានចេញ ទាំងអង្គបុរេជំនុំជម្រះ និងការិយាល័យដទៃទៀតរបស់ អ.វ.ត.ក មិនបានចេញសេចក្ដីពន្យល់ច្បាស់លាស់ជាសាធារណៈ ទាក់ទងនឹងស្ថានភាពនៃសំណុំរឿង ០០៤/២ ឬវិធីសាស្ត្រក្នុងការបន្តទៅមុខឡើយ។ អនុស្សរណៈអន្តរការិយាល័យប្រទាំងប្រទើសគ្នាបន្ថែមទៀតដែលបានចេញដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ និងដោយចៅក្រមប្រធានអង្គបុរេជំនុំជម្រះ ក្នុងនាមផ្ទាល់ខ្លួនរបស់គាត់ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ បានធ្វើឱ្យបញ្ហានេះកាន់តែយ៉ាប់យ៉ឺនទៀត។ នាពេលថ្មីៗនេះ ការចេញសេចក្ដីថ្លែងការណ៍ជូនព័ត៌មានរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹងស្ថានភាពនៃសំណុំរឿងនេះ គឺជាការព្យាយាមយ៉ាងច្បាស់ក្រឡែតក្នុងការជូនដំណឹងទៅដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែការដាក់បញ្ចូលមតិយោបល់របស់ចៅក្រមជាតិនៃអង្គជំនុំជម្រះនេះដែលថា "នឹងមិនមានការជំនុំជម្រះក្ដីលើ អោ អាន នៅពេលនេះ ឬ នៅពេលអនាគតនោះ គឺគ្រាន់តែធ្វើឱ្យមានការភាន់ច្រឡំបន្ថែមទៀត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីដែលកំពុងដំណើរការ។ ការមិនមានភាពច្បាស់លាស់នៅក្នុងលិខិតឆ្លើយឆ្លងទាំងនេះបង្កើតបានជាការរំលោភបំពានយ៉ាងច្បាស់ទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងសិទ្ធិទទួលបានព័ត៌មានច្បាស់លាស់ មានតម្លាភាព និងទាន់ពេលវេលា ដែលបណ្ដាលឱ្យដើមបណ្ដឹងរដ្ឋប្បវេណី មិនដឹងច្បាស់លាស់អំពីស្ថានភាពនៃសំណុំរឿង ០០៤/២ និងសិទ្ធិរបស់ខ្លួននាពេលខាងមុខ។

### *ខ. អ.ជ.ត.ក មានភារកិច្ចការពារសេចក្ដីថ្លៃថ្នូរ និងសុខមាលភាពជនរងគ្រោះ ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក*

62. នេះជាគោលការណ៍ជាសារវន្តនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលថា ផលប្រយោជន៍របស់ជនរងគ្រោះ ត្រូវបានការពារ[95]។ ការសម្របសម្រួលរបបនៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក គឺជាគោលការណ៍ច្បាប់អន្តរជាតិ ដែលទទួលស្គាល់ និងឆ្លើយតបចំពោះភាពងាយទទួលរងគ្រោះ និងការប៉ះទង្គិច ដែលជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងអំពើសាហាវយង់ឃ្នង

[95] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ (ធ្វើវិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)។

ជាទ្រង់ទ្រាយធំបានទទួលរង ហើយមានចេតនាដើម្បីរាំងរាំងព្យសនកម្មចំពោះជនរងគ្រោះ ដែលព្យសនកម្មនោះ ជាផលវិបាកនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌។ និយាមអន្តរជាតិដែលគ្រប់គ្រងលើដំណើរការតុលាការ បានអំពាវនាវឲ្យប្រព្រឹត្តចំពោះជនរងគ្រោះដោយយកចិត្តទុកដាក់ ដោយមេត្តា និងគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ដែលពួកគាត់ត្រូវទទួលបានការយកចិត្តទុកដាក់ និងការថែទាំជាពិសេស ដើម្បីកុំឲ្យពួកគាត់ជួបប្រទះការប៉ះទង្គិចសារជាថ្មី និងដើម្បីការពារពួកគាត់ឲ្យរួចផុតពីព្យសនកម្មរូបរាងកាយ និងផ្លូវចិត្ត[96]។

63. ដូចដែលបានរៀបរាប់លម្អិតនៅក្នុងសារណានេះ ឧបសគ្គចំពោះការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព គឺ ការចែករំលែកព័ត៌មានមិនបានគ្រប់គ្រាន់ជាមួយជនរងគ្រោះ ព្រមទាំងការមិនមានតម្លាភាព និងសច្ចភាពផ្លូវច្បាប់ ដែលស្ថិតនៅក្នុងការជាប់គាំង ដែលកំពុងតែបន្តក្នុងសំណុំរឿង ០០៤/២ ដែលបណ្តាលឲ្យមានព្យសនកម្មចំពោះជនរងគ្រោះ ជារៀងរហូត និងមិនអាចអនុញ្ញាតបាន។ **ប្រសិនបើអនុញ្ញាតឲ្យបន្តទៅទៀត កាលៈទេសៈទាំងអស់នេះនឹងមិនគ្រាន់តែបង្កើតឲ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងជាបន្ត ចំពោះសិទ្ធិរបស់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កហានិភ័យនៃការប៉ះទង្គិចសារជាថ្មី ចំពោះជនរងគ្រោះ ដែលធ្វើឲ្យប៉ះពាល់ដល់ជំនឿ និងការទុកចិត្តរបស់ពួកគាត់ នៅក្នុងដំណើរការរបស់តុលាការ និងធ្វើឲ្យអន្តរាយដល់ការចូលរួមចំណែកក្នុងការបង្រួបបង្រួមជាតិ ដែល អ.វ.ត.ក អាចបង្កើតឡើង ហើយ*បញ្ជូនសារ ដែលមានលក្ខណៈអវិជ្ជមានយ៉ាងខ្លាំងថា តុលាការមិនគោរពសិទ្ធិរបស់ជនរងគ្រោះ មិនផ្តល់តម្លៃដល់ការចូលរួមរបស់ជនរងគ្រោះ ឬមិនយល់អំពីការឈឺចាប់របស់ជនរងគ្រោះ*។**

64. អ.ជ.ត.ក មានអំណាចក្នុងការសម្រាល ឬបញ្ចៀសកុំឲ្យមានព្យសនកម្មឥតប្រយោជន៍ទាំងនេះដល់ជនរងគ្រោះ តាមរយៈការកែតម្រូវកំហុសរបស់ អ.ជ.ស.ង ដែលបានខកខានអនុញ្ញាតឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះ អោ អាន បន្តនីតិវិធីទៅជំនុំជម្រះ ដូចមានចែងនៅក្នុងក្របខណ្ឌគតិ

[96] សូមមើល គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១០ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ U.N.G.A. Res. 60/147។ សេចក្តីប្រកាសលើគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច កថាខណ្ឌ ៦(ក),(ង) U.N.G.A. Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ ឧបសម្ព័ន្ធ ក.១។ លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦៨, ៧៥ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨ 2187 U.N.T.S. 90។

យុត្តិរបស់ អ.វ.ត.ក និងតាមរយៈការដោះស្រាយការរំលោភបំពានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ជនរងគ្រោះដែលបានកើតឡើងនៅក្នុងកិច្ចដំណើរនីតិវិធីទាំងនេះ។

## III. សេចក្តីសន្និដ្ឋាន

65. សហមេធាវីសូមអះអាងដោយគោរពថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយសារខកខានមិនបានទទួលស្គាល់ថា ខ្លួនបានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន។ ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក តម្រូវឱ្យបន្តកិច្ចដំណើរការនីតិវិធីទៅមុខក្នុងករណីពុំមានសេចក្តីសម្រេចច្បាស់លាស់របស់ អ.ប.ជ។ បទដ្ឋាននេះត្រូវបានបង្កើតឡើងយោងតាមអត្ថន័យត្រង់ៗ នៅក្នុងកិច្ចព្រមព្រៀង អ.ត.វ.ក និងច្បាប់ អ.វ.ត.ក កម្មវត្ថុ និងគោលបំណងរបស់សាលាក្តីក្នុងការកាត់ក្តីអំពើឃោរឃៅធំៗរបស់ខ្មែរក្រហម និងគោលការណ៍ច្បាប់ក្នុងស្រុក និងអន្តរជាតិ ដែលសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់ជនរងគ្រោះ និងកាតព្វកិច្ចក្នុងការកាត់ទោស។ អ.ជ.ត.ក មានកាតព្វកិច្ចសម្រេចលើកំហុសអង្គច្បាប់នេះ និងការពារសិទ្ធិរបស់ជនរងគ្រោះ ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។

66. អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំអង្គជំនុំជម្រះតុលាការកំពូល៖

ក. សម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២។

ខ. បង្គាប់ឱ្យផ្ទេរសំណុំរឿង ០០៤/២ ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង

គ. បង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូង ផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង ០០៤/២ ឱ្យបានត្រឹមត្រូវជាបន្ទាន់ និងសម្រេចវិនិច្ឆ័យសំណុំរឿងនេះឱ្យបានឆាប់រហ័ស។

ឃ. បង្គាប់វិធានការរដ្ឋបាលផ្សេងៗ ដែលចាំបាច់ដើម្បីសម្រួលដល់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

ង. ទទួលស្គាល់ការរំលោភបំពានធ្ងន់ធ្ងរ និងការបន្តរំលោភសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ និងដោះស្រាយការរំលោភបំពានទាំងនេះឱ្យបានសមស្រប និង

០០៤/២/០៧-០៩-២០០៩-អវតក-អជសដ/អជតក

ច. ចេញ ឬ បង្គាប់ឱ្យចេញ ដោយការិយាល័យសមស្របរបស់ អ.វ.ត.ក នូវសេចក្តីថ្លែងការណ៍ជាសាធារណៈឱ្យបានច្បាស់លាស់អំពីស្ថានភាពបច្ចុប្បន្ននៃសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ដែលបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក ក៏ដូចជាជំហានបន្ទាប់ ដែលរំពឹងទុកថានឹងយកមកដោះស្រាយភាពជាប់គាំងផ្នែកនីតិវិធីបច្ចុប្បន្ន។

សូម លោក/លោកស្រីចៅក្រម ទទួលយកសេចក្តីសន្និដ្ឋាននេះដោយសេចក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | ហុង គីមសួន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | ឡោ ជុនធី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | សំ សុគង់ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | Emmanuel JACOMY | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | Martine JACQUIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Me Martine JACQUIN |
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | Daniel MCLAUGHLIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| [កាលបរិច្ឆេទ] ឆ្នាំ ២០២០ | Nushin SARKARATI | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |